F15

...ដើម្បីរ...
A C T

Sustainable Livelihoods

# សម្លេងប្រជានេសាទ

## បរិស្ថាន ធនធានធម្មជាតិ ទឹក និង មនុស្ស

*Environment, Natural Resources, Water & People*



**ជីវិតសត្វស្លាបទឹកក្នុងខេត្តកំពង់ធំ កំពុងទទួលរងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ**

**ទូកនេសា...**
**ទូកសប្បាយ...**

**ភាពស្មុគស្មាញនៃបញ្ហានេសាទសមុទ្រ និង ផលវិបាកដល់ជីវភាពប្រចាំថ្ងៃរបស់អ្នកស្ទឹងហាវ**

# សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល
## *Fisheries Action Coalition Team (FACT)*

សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល ***(FACT)*** ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ដោយក្រុមអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិមួយក្រុម ដែលធ្វើការពាក់ព័ន្ធទៅនឹងបញ្ហាបរិស្ថាន និងការនេសាទនៅជុំវិញបឹងទន្លេសាប ហើយក៏ជាបណ្តាញនៃអង្គការមិនមែនរដ្ឋាភិបាលមួយ ធ្វើការនៅជុំវិញបឹងទន្លេសាប ទន្លេមេគង្គ និងតំបន់ឆ្នេរសមុទ្រ ពាក់ព័ន្ធនឹងបរិស្ថាន ធនធានធម្មជាតិ និងជលផលនៃប្រទេសកម្ពុជា។ សម្ព័ន្ធភាពនេះត្រូវបានបង្កើតឡើងជាផ្នែកមួយនៃគំរោងបរិស្ថានរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា *(NGO Forum on Cambodia)* ។

សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល ***(FACT)*** កំពុងធ្វើការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលចំនួន២២ នៅក្នុងខេត្តចំនួន៩ ព្រមទាំងតំណាងសហគមន៍នេសាទចំនួន៣៥ មកពីខេត្តជុំវិញបឹងទន្លេសាប ទន្លេមេគង្គភាគខាងលើ និងភាគខាងក្រោម ។ ពត៌មានបន្ថែម សូមចូលទៅគេហទំព័ររបស់ ***FACT*** គឺ ***www.fact.org.kh*** ។

សកម្មភាពចំបងរួមមានការកសាងសមត្ថភាពដល់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលនិងពង្រឹងអង្គការសហគមន៍នៅថ្នាក់មូលដ្ឋាន។ សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល ***(FACT)*** ធ្វើការពាក់ព័ន្ធនៅក្នុងការសិក្សាស្រាវជ្រាវ និងប្រមូលពត៌មានទៅលើបញ្ហាបរិស្ថាន ធនធានធម្មជាតិ ការនេសាទ និងជាពិសេសធ្វើការជាមួយបណ្តាញអង្គការមិនមែនរដ្ឋាភិបាលនៅតាមខេត្តនានាជុំវិញបឹងទន្លេសាប ដើម្បីជំរុញឱ្យមានការជជែកពិភាក្សាលើបញ្ហាបរិស្ថាន និងជលផលពីអ្នកដែលពាក់ព័ន្ធនានា។ តាងនាមអោយគណៈកម្មការនិពន្ធ និងស្រាវជ្រាវ យើងខ្ញុំសូមឧទ្ទិសអោយសំលេងប្រជានេសាទលេខនេះបានដឹងឮទៅដល់អ្នកធ្វើសេចក្តីសំរេចចិត្តផ្នែកនយោបាយ និងអ្នកដឹកនាំកំពូលៗ ដើម្បីអោយមានអន្តរាគមន៍សមស្របណាមួយដើម្បីជាកិច្ចការពារសម្បត្តិធម្មជាតិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយើងផង ។

**សូមអរគុណ !**

# ទស្សនាវដ្តី សំឡេងប្រជានេសាទ

## បរិស្ថាន ធនធានធម្មជាតិ ទឹក និងមនុស្ស

Environment, Natural Resources, Water, and People


**ចេញផ្សាយដោយសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល**

**Fisheries Action Coalition Team (FACT)**

**គណៈកម្មការត្រួតពិនិត្យ**

លោក ម៉ក់ សិទ្ធីរិទ្ធ (FACT)
លោក វ៉ាន់ ពិសិដ្ឋ (FACT)
លោក ឱម សាវ៉ាត (CFDS)
លោក ស៊ឹម ប៊ុនធឿន ( Oxfam US)
លោក ឈិត សំអាត ( CIDSE )

**ក្រុមអ្នកនិពន្ធ និងស្រាវជ្រាវ**

លោក ជិន វុឌ្ឍី (FACT)
លោក ឯម ច័ន្ទណារិទ្ធ (FACT)
លោក ហឿន ហ៊ុន្នី (FACT)
លោក ចាន់ រដ្ឋា (FACT/AFSC)
លោក តែ សុខឃឿន
លោក ប៉ែន រង្សី
លោក ស្វាយ ភិរុណ
លោក ឈឹម សោភ័ក្រ

**ចែកចាយ**

ដោយបណ្តាញអង្គការមិនមែនរដ្ឋាភិបាលនៅខេត្ត កំពង់ឆ្នាំង, ពោធិសាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប, កំពង់ធំ

**ឧបត្ថម្ភថវិកា**

FOS, Oxfam America, HBF

**បោះពុម្ពដោយ**

រោងពុម្ព សេវាពន្លឺពេជ្របោះពុម្ព
ចំនួន ១៥០០ ច្បាប់


# មាតិកា

ទំព័រ


- ធនធានជលផលថយចុះបានបង្ខំអ្នកនេសាទនៅបឹងទន្លេសាបបែរទៅរកជំរើសថ្មី ............ ០១
- ការធ្លាក់ចុះនៃទិន្នផលត្រីបណ្តាលអោយមានផលប៉ះពាល់ដល់ជីវភាពប្រជានេសាទ នៅឃុំចុងឃ្នៀស ខេត្តសៀមរាប ............ ០៣
- ជីវិតអ្នកនេសាទក្រីក្រផ្ញើរលើព្រលិត និងខ្យង ............ ០៦
- ភាពចំរូងចំរាស់ចំពោះការផ្លាស់ប្តូរតំណែងប្រធានសហគមន៍ចាស់នៅអន្លង់សំណរ ............ ០៨
- បញ្ហាប្រឈមមុខលើការជំលៀសប្រជាពលរដ្ឋចេញពីភូមិពាក់កន្លែល ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង............ ១០
- ទូកនេសាទជនជាតិវៀតណាមរាប់រយទូកសប្បាយនឹងការនេសាទត្រីប្រាខ្ចៅ............ ១២
- តំបន់អភិរក្សធនធានមច្ឆាជាតិ ភូមិព្រែកត្រប់ ឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ កំពុងធ្វើអោយមានការភ្ញាក់ផ្អើលដល់សធារណៈជន............ ១៥
- ជីវិតសត្វស្លាបទឹកក្នុងខេត្តកំពង់ធំ កំពុងទទួលរងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ............ ១៧
- ភាពស្មុគ្រស្មាញនៃបញ្ហានេសាទសមុទ្រ និងផលវិបាកដល់ជីវភាពប្រចាំថ្ងៃរបស់អ្នកស្ទឹងហាវ ............ ១៩
- ការត្អូញត្អែររបស់ប្រជានេសាទបង្គានៅភូមិអន់ឆ្អឹត............ ២២
- អ្នកភូមិអន់ឆ្អឹតមានសង្ឃឹម ក្រោយពីការបង្កើតសហគមន៍នេសាទ ............ ២៤
- វេទិការប្រជានេសាទ ............ ២៥
- ***អត្ថបទស្រាវជ្រាវ:*** អត្ថបទសង្ខេបពីសារពត៌មាននានាស្តីអំពីបញ្ហាវិស័យជលផល ខែ កក្កដា សីហា ឆ្នាំ ២០០៤ ............ ៣៣
- ***កំណាព្យ:*** ខ្ញុំអ្នកឆក់ត្រី............ ៣៥

# ធនធានជលផលថយចុះបានបង្ខំអ្នកនេសាទ នៅបឹងទន្លេសាបបែរទៅរកជំរើសថ្មី

**អត្ថបទៈ តែ សុខឃឿន**

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះធនធានជលផលនៅបឹងទន្លេសាបមានការថយចុះជាពិសេសផលស្តុកត្រីក្នុងធម្មជាតិដែលបានជះឥទ្ធិពលលើការិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅពឹងផ្អែកលើការនេសាទត្រី។ ជាក់ស្តែងប្រជានេសាទក្នុងភូមិតាមល់លើ ឃុំកោះថ្កូវ ស្រុកជលគីរី ខេត្តកំពង់ ឆ្នាំង ប្រមាណ១៤% នៃប្រជាពលរដ្ឋសរុបក្នុងភូមិបានផ្លាស់ប្តូរទីលំនៅរបស់ខ្លួន និងមុខរបរនេសាទត្រីទៅធ្វើកម្មករនៅក្នុងប្រទេសនិងក្រៅប្រទេស ។

លោក **អេង ទី** ប្រជាពលរដ្ឋភូមិតាមល់លើ ឃុំកោះថ្កូវ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង មានប្រសាសន៍ថា "ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាពលរដ្ឋក្នុងភូមិបានកើតឡើងនៅគ្រប់រដូវនេសាទត្រីជារៀងរាល់ឆ្នាំជាពិសេសនៅក្នុងឆ្នាំ ២០០៤ នេះតែម្តង ។ មូលហេតុទាំងអស់នេះដោយប្រជាពលរដ្ឋទាំងអស់នោះយល់ឃើញថាប្រភពធនធានជលផលពីមួយថ្ងៃទៅមួយថ្ងៃកាន់តែរិចរិលទៅៗ និងនេសាទមិនបានសំរាប់ចិញ្ចឹមជីវិតគ្រួសារ។ ភាពលំបាកទាំងអស់នេះ បានអូសបន្លាយពីរដូវនេសាទត្រីនៅក្នុងឆ្នាំ ២០០៣ ហើយវាបានបន្តរហូតដល់បច្ចុប្បន្ននេះដោយក្នុងនោះបានជំរុញឱ្យប្រជានេសាទចំនួន១៤%ក្នុងចំណោមប្រជាពលរដ្ឋសរុបក្នុងភូមិត្រូវតែបង្ខំចិត្តចាកចេញពីភូមិកំណើតរបស់ខ្លួនទៅរកទីតាំងលំនៅថ្មី និងចាប់យកមុខរបរលក់កំលាំងពលកម្មឱ្យគេ "។


ថតដោយ : តែ សុខឃឿន

**លោក អេង ទី**

លោក **ស៊ូ សឿង** ប្រធានភូមិតាមល់លើ ឃុំកោះថ្កូវ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង មានប្រសាសន៍ថា " ប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេសាបរស់នៅដោយធ្វើរបរកសិកម្ម និងនេសាទត្រីជាសំខាន់។ ប្រជាពលរដ្ឋក្នុងភូមិតាមល់លើមិនមែនសុទ្ធតែមានដីស្រែផ្ទាល់ខ្លួនសំរាប់ធ្វើកសិកម្មទាំងអស់គ្នានោះទេ ប្រជាពលរដ្ឋដែលគ្មានដីស្រែ ពួកគាត់នឹងធ្វើការនេសាទត្រីជារបរសំខាន់ ទន្ទឹមនឹងនេះយើងដឹងហើយថា ធនធានជលផលរបស់យើងត្រូវបានថយចុះយ៉ាងខ្លាំងដែលធ្វើឱ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋគ្មានដីស្រែ។ ក្នុងករណីនេះទោះបីជាពួកគាត់ចង់ រឺមិនចង់ ចាំបាច់ត្រូវធ្វើចំណាកស្រុកទៅរស់នៅកន្លែងផ្សេងៗដើម្បីធ្វើយ៉ាងណាឱ្យជីវភាពរស់នៅរបស់ពួកគេមានភាពល្អប្រសើរជាងមុន "។

លោកប្រធានភូមិបានបន្ថែមទៀតថា " ដើម្បីទប់ទល់នឹងបញ្ហានេះបានលុះត្រាតែសហគមន៍នេសាទត្រូវបានទទួលសិទ្ធិបង្ក្រាបលើអ្នកល្មើសនេសាទ និងលក្ខន្តិកៈរបស់សហគមន៍នេសាទត្រូវបានគេទទួលស្គាល់ដោយច្បាប់ និងពីអ្នកពាក់ព័ន្ធទាំងអស់។ ពេលនោះហើយ ដែលធនធានជលផល

ពិតជាអាចនឹងត្រលប់មករកភាពដើមវិញដូចកាលដែលសហគមន៍នេសាទមិនទាន់មានបញ្ហាជាមួយពួកនេសាទ



ថតដោយ : តៃ សុខឿន

**លោក ស៊ូ សឿង**

ល្មើសច្បាប់ក្នុងឆ្នាំ ២០០៣ ដូច្នោះដែរ ”។

តាមរយៈការសំភាសន៍ប្រជាពលរដ្ឋចំនួន១០គ្រួសារ ក្នុងភូមិតាមល់លើបានអោយដឹងថា ពួកគាត់បានទទួលស្គាល់ពីការថយចុះនូវប្រភពធនធានជលផលស្ទើរតែទាំងស្រុង ដោយមានមូលហេតុជាច្រើនអាចបណ្តាលមកពីអ្នកអនុវត្តន៏ច្បាប់ និងអ្នកទទួលយកនូវឥទ្ធិពលច្បាប់ដែលពាក់ព័ន្ធក្នុងវិស័យជលផលអនុវត្តពុំសូវមានប្រសិទ្ធិភាពខ្លាំងក្លា ក្នុងនោះលក្ខន្តិកៈសហគមន៍នេសាទ ក៏មិនត្រូវបានទទួលស្គាល់ពីភ្នាក់ងាររដ្ឋាភិបាល និងអាជ្ញាធរ ដោយអ្នកពាក់ព័ន្ធសំអាងលើពង្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទមិនទាន់ចេញជាផ្លូវការ។ ក្នុងករណីនេះហើយទើបសហគមន៍នេសាទចុះបង្ក្រាបបទល្មើសនេសាទជាក់ស្តែងក្នុងដែនសហគមន៍ត្រូវក្លាយជាអ្នកមានទោសដោយត្រូវរងការចោទប្រកាន់ពីតុលាការខេត្តអំពីសកម្មភាពបង្ក្រាបរបស់ខ្លួន ។

---

**តមកពីទំព័រ ៩**

**ភាពជ្រួលច្របល់ចំពោះការ....**



ថតដោយ : ប៉ែន រង្សី

**លោក សាយ ស៊ីថា**

ល្មើសនេសាទដូចជា អ៊ុយស្បៃមុង និងឧបករណ៍ខុសច្បាប់ជាច្រើនទៀត។ ទាក់ទងនឹងការផ្លាស់ប្តូរតំណែងសហគមន៍នេសាទ លោកបានមានប្រសាសន៏ថា ការបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មីនេះនឹងនាំឱ្យមាននូវអំពើរពុករលួយកាន់តែខ្លាំង ព្រោះគណៈកម្មការសហគមន៍ថ្មីភាគច្រើនជាអ្នកប្រព្រឹត្តបទល្មើសឃុបឃិតជាមួយមន្ត្រីខិលខូចមួយចំនួន គឺគ្មានគំនិតថែរក្សាធនធានឡើយ។ បច្ចុប្បន្នដោយសារសហគមន៍ឋិតនៅក្នុងដំណាក់កាលច្របូកច្របល់ និងឋិតនៅក្នុងការជ្រើសរើសគណៈ-កម្មការសហគមន៍ បានធ្វើអោយសហគមន៍ចាស់ត្រូវផ្អាកដំណើរការបង្ក្រាបបទល្មើសមួយរយៈសិន។ កត្តានេះបានជំរុញអោយមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំង ដោយសារអ្នកប្រព្រឹត្តបទល្មើសបានកើនជាលំដាប់នៅក្នុងដែននេសាទសហគមន៍ លោកបានសំនូមពរដល់រាជរដ្ឋាភិបាល សូមពិនិត្យមើលអោយបានល្អិតល្អន់ និងសុំអោយមន្ត្រីជលផលអនុវត្តច្បាប់អោយមានប្រសិទ្ធិភាព ជាពិសេសការបង្ក្រាបបទល្មើសនៅរដូវបិទនេសាទ។ លោកបានបញ្ជាក់ថា ប្រសិនបើមន្ត្រីជំនាញពង្រឹងការអនុវត្តច្បាប់នោះ ខ្ញុំជឿជាក់ថាប្រជាពលរដ្ឋពិតជាពុំហ៊ានប្រព្រឹត្តបទល្មើសឡើយ ជាពិសេសយើងចង់អោយខាងជំនាញចូលរួមសហការអោយជិតស្និត ទើបសហគមន៍អាចថែរក្សាធនធានបាន ។

# ការធ្លាក់ចុះនៃទិន្នផលត្រីបណ្តាលអោយមានផលប៉ះពាល់ដល់ជីវភាពប្រជានេសាទ នៅឃុំចុងឃ្នៀស ខេត្តសៀមរាប

**ប្រជាជនរស់នៅក្នុងឃុំចុងឃ្នៀស ភាគច្រើនប្រកបរបរនេសាទដើម្បីចិញ្ចឹមជីវិត ដោយសារផលិតផលត្រីនាពេលបច្ចុប្បន្ននេះមានការធ្លាក់ចុះយ៉ាងខ្លាំង ដែលបណ្តាលមកពីមានការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់នៅក្នុងរដូវបិទនេសាទការ កាប់ព្រៃលិចទឹក និងការកើនឡើងនៃចំនួនអ្នកនេសាទបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ផលិតផលត្រីថយចុះ ហើយដែលកំពុងតែគំរាមគំហែងដល់ជីវភាព និងបង្ខំអោយមានការបាត់បង់នូវមុខរបរដ៏សំខាន់ដែលធ្លាប់តែផ្តល់នូវចំណូលយ៉ាងច្រើនសន្ធឹកសន្ធាប់ ។**

**អត្ថបទដោយៈ ក. ទាប សុផារី**

ឃុំចុងឃ្នៀស គឺជាឃុំមួយក្នុងចំណោមឃុំទាំង១០ នៃស្រុកសៀមរាប ខេត្តសៀមរាប ដែលមានព្រំប្រទល់ខាងកើតទល់នឹងឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគងខាងជើងទល់នឹងឃុំជ្រាវ ឃុំសៀមរាប និងឃុំសំបួរក្នុងស្រុកសៀមរាប ខាងលិចទល់នឹងឃុំកែវពណ៌ស្រុកពួក និងខាងត្បូងទល់នឹងបឹងទន្លេសាប។ ប្រជាជនរស់នៅក្នុងឃុំចុងឃ្នៀសមានចំនួនសរុប ១១០១គ្រួសារ ដែលក្នុងនោះប្រមាណជា៧៥ភាគរយរស់នៅពឹងផ្អែកទាំងស្រុងទៅលើប្រភពធនធានធម្មជាតិ ជាពិសេសគឺធនធានមច្ឆជាតិ ព្រោះថាធនធាននេះមានសារៈសំខាន់យ៉ាងចំបងសំរាប់ផ្គត់ផ្គង់នូវម្ហូបអាហារក្នុងស្រុកជាប្រភពផ្តល់នូវប្រាក់ចំណូល និងផ្តល់នូវការងារផងដែរ ។ ប្រជាជនរស់នៅក្នុងឃុំចុងឃ្នៀស ភាគច្រើនប្រកបរបរនេសាទដើម្បីចិញ្ចឹមជីវិតដោយសារផលិតផលត្រីនាពេលបច្ចុប្បន្ននេះមានការធ្លាក់ចុះយ៉ាងខ្លាំង ដែលបណ្តាលមកពី មានការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់នៅក្នុងរដូវបិទនេសាទ ការកាប់ព្រៃលិចទឹក និងការកើនឡើងនៃចំនួនអ្នកនេសាទបានជះឥទ្ធិពលយ៉ាងខ្លាំង ដល់ផលិតផលត្រីថយចុះ ហើយដែលកំពុងតែគំរាមគំហែងដល់ជីវភាព និងបង្ខំអោយមានការបាត់បង់នូវមុខរបរដ៏សំខាន់ដែលធ្លាប់តែផ្តល់នូវចំណូលយ៉ាងច្រើនសន្ធឹកសន្ធាប់ ។



ថតដោយ : ប៉ែន រង្សី

**លោក ឯម ម៉ាន**

នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ស្ថានភាពផលិតផលត្រីកំពុងថយចុះយ៉ាងខ្លាំង ហើយឃុំចុងឃ្នៀសក៏ជាឃុំមួយដែលទទួលនូវផលប៉ះពាល់នេះផងដែរ ជាក់ស្តែងតាមការចុះសាកសួររបស់ក្រុមស្រាវជ្រាវពតិមានរបស់សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) បានស្រង់នូវទស្សនៈដើម ទាំងស្រុងរបស់ប្រធាននិងអនុប្រធានឃុំចុងឃ្នៀស និងអាជីវករលក់ត្រីដែលទើបតែផ្លាស់ប្តូរមុខរបរដោយសារខ្សត់ត្រី និងតំលៃត្រីឡើងខ្ពស់ដែលពិបាកក្នុងរកប្រាក់ចំណូល ។

លោក **ឯម ម៉ាន** មេឃុំចុងឃ្នៀស បានមានប្រសាសន៍ថា " ទិន្នផលត្រីនាពេលបច្ចុប្បន្ននេះមានការធ្លាក់ចុះយ៉ាងខ្លាំងគួរអោយព្រួយបារម្ភ



ថតដោយ : ប៉ែន រង្សី

**របាំងឬស្សីលបែលដាក់នេសាទនៅក្នុងរដូវបិទនេសាទ ក្នុងសហគមន៍អន្លង់សំណរ**

ដែលបណ្តាលមកពីមូលហេតុមួយចំនួន-ដូចជា ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់រួមមានលបណរ៉ាវ អ៊ុយស្បៃមុង និងឧបករណ៍ឆក់ ដែលធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់ធនធានជលផល។ ដោយឡែកនៅក្នុងរដូវបិទនេ-សាទឆ្នាំនេះបទល្មើសនេសាទមិនមានមានការថយចុះទាល់តែសោះក្នុងការប្រើប្រាស់នូវឧបករណ៍ល្មើសទាំងនោះផ្ទុយទៅវិញ ការប្រើប្រាស់នូវឧបករណ៍អ៊ុយស្បៃមុងមានការកើនឡើងច្រើនជាងក្នុងរដូវបើកនេសាទទៅទៀតដែលជាកត្តាមួយជំរុញអោយផលិតផលត្រីក្នុងតំបន់នោះកាន់តែវិនាសហិនហោចយ៉ាងធ្ងន់ធ្ងរ។ ម្យ៉ាងទៀតការធ្លាក់ចុះនេះក៏បណ្តាលមកពីចំនួនអ្នកនេសាទមានការកើនឡើង និងការកាប់បំផ្លាញនូវធនធានព្រៃលិចទឹកមួយចំនួនដែលជាជំរក និងជាកន្លែងពងកូនរបស់ហ្វូងមច្ឆាជាតិទាំងនោះ។ គួររំលឹកផងដែរថាតាមការ សិក្សាស្រាវជ្រាវរបស់នាយ-កដ្ឋានជលផល ថ្មីៗនេះបានបញ្ជាក់ថាការបាត់បង់ព្រៃលិចទឹកចំនួន១០% អាចបណ្តាលអោយបរិមាណផលចាប់មានការធ្លាក់ចុះ១០%ដែរ ។

កត្តាខាងលើនេះ ធ្វើអោយជីវភាពរបស់ប្រជានេសាទមានការធ្លាក់ចុះយ៉ាងខ្លាំង ដែលក្នុងនោះមានប្រជាជនប្រហែល៧០០ គ្រួសារ ហើយឈានទៅរកការអត់ឃ្លាន ព្រោះរាល់ឆ្នាំ គាត់នេសាទត្រី បាន ២-៣តោន ប៉ុន្តែនាពេលបច្ចុប្បន្ននេះ នេសាទបានតិចណាស់ គឺត្រឹមតែ១តោនប៉ុណ្ណោះ ដូច្នេះ ប្រជានេសាទមួយចំនួន ត្រូវតែបង្ខំចិត្តបានអោយកូនចៅរបស់ពួកគេឈប់រៀន ហើយទៅជួយធ្វើនេសាទ ឬលក់ដូរអ្វីផ្សេងៗទៀតដើម្បីទទួលបានប្រាក់ចំណូលបន្ថែមខ្លះសំរាប់បំពេញនូវកង្វះខាតសំរាប់ការចិញ្ចឹមជីវិតប្រចាំថ្ងៃ ។

លោក **ទូច សុផាត** ជំទប់ទី២ នៃឃុំចុងឃ្មៀសបានមានប្រសាសន៍ផងដែរថា " ផលិតផលត្រីក្នុងឆ្នាំ២០០៤ នេះមានការធ្លាក់ចុះយ៉ាងខ្លាំង " គឺបណ្តាលមកពីមានបទល្មើសនេសាទជាច្រើនករណីបានកើតឡើងដោយឥតឈប់ឈរមិនថានៅក្នុងរដូវបិទ ឬបើកនេសាទទេ ព្រោះថា មន្ត្រីជំនាញមួយចំនួនបានទទួលសំណូកពីសំណាក់ប្រជានេសាទដែលប្រព្រឹត្តបទល្មើសទាំងនោះ។ លោកបានបន្តទៀតថា ការនេសាទដោយប្រើប្រាស់នូវឧបករណ៍ឆក់ ស្បៃមុង និងមងក្រលាញ៉ឹក មិនត្រឹមតែចាប់នូវត្រីធំៗដែលជាតម្រូវការរបស់ប្រជាជនប៉ុណ្ណោះទេតែថែមទាំងបានសំលាប់នូវត្រីតូចៗ



ថតដោយ : ប៉ែន រង្សី

**លោក ទូច សុផាត**



ថតដោយ : ប៉ែន រស្មី

**អ្នកមីង មាស ម៉ៅ**

ថែមទៀតផង។ ការធ្លាក់ចុះនៃផលនេសាទនេះបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជីវភាពរបស់ប្រជានេសាទ ដែលកំពុងតែប្រឈមមុខទៅនឹងការបាត់បង់នូវមុខរបរដ៏សំខាន់ដែលធ្លាប់តែផ្តល់នូវចំណូលយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

លោកបានសំណូមពរអោយរាជរដ្ឋាភិបាលអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធមេត្តាយកចិត្ត ទុកដាក់អោយបានខ្លាំងក្លាថែមទៀត លើការគ្រប់គ្រងធនធានជលផល ដែលកំពុងតែទទួលរងនូវការបំផ្លិចបំផ្លាញពីសំណាក់ជនល្មើស និងមន្ត្រីខិលខូចមួយចំនួនអោយបានប្រសើរឡើងវិញ ។

អ្នកមីង **មាស ម៉ៅ** អតីតអាជីវករលក់ត្រីនៅផ្សារខេត្តសៀមរាប ដែលគាត់បានប្រកបមុខរបរនេះជាច្រើនឆ្នាំមក ហើយបានមានប្រសាសន៍ថា " ការពីមុនត្រីសំបូរហូរហៀរណាស់ ប៉ុន្តែចាប់ពីឆ្នាំ ២000 ដល់ឆ្នាំ ២00៣ ទិន្នផលត្រីចាប់ផ្តើមថយចុះបន្តិចម្តងៗ ជាពិសេសក្នុងឆ្នាំនេះមានការថយចុះយ៉ាងខ្លាំងគួរអោយព្រួយបារម្ភដែលជាមូលហេតុជំរុញអោយគាត់ផ្លាស់ប្តូរពីមុខរបរលក់ត្រីទៅលក់ទឹកកកវិញ ព្រោះគាត់រកទិញត្រីពីប្រជានេសាទមិនបាន ហើយតំលៃត្រីក៏ឡើងខ្ពស់ខ្លាំងដែលធ្វើអោយគាត់ពិបាកលក់ទៅអោយអតិថិជនមួយចំនួន។

អ្នកមីងបានបន្ថែមទៀតអំពីការព្រួយបារម្ភមួយចំនួនទៅលើធនធានមច្ឆានៅបឹងទន្លេសាបបច្ចុប្បន្នដែលកំពុងតែឈានទៅរកការវិនាសហិនហោច និងមានតម្លៃនៅតែថ្លៃកាន់តែថ្លៃ២ទៅ៣ដង បើប្រៀបធៀបទៅពីមុន។ ជាក់ស្តែងប្រជាជនកម្ពុជាភាគច្រើន គឺស្ថិតនៅក្នុងភាពក្រីក្រនៅឡើយ ជាពិសេសប្រជាជននៅតាមជនបទ ហើយប្រសិនបើត្រីថយចុះ និងតម្លៃកាន់តែកើនឡើងបែបនេះ គឺធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំងទៅដល់ប្រជាជនទាំងនោះ ។ ដូច្នេះសំនូមពរទៅដល់រាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នពាក់ពន្ធ័មេត្តាជួយធ្វើយ៉ាងណាអោយត្រីនៅបឹងទន្លេសាបមានភាពសំបូរឡើងវិញសំរាប់អោយកូនចៅជំនាន់ក្រោយ ដើម្បីធ្វើការចិញ្ចឹមជីវិតបន្តទៀតនៅពេលអនាគត ជាពិសេសសូមអោយមានវិធានការទប់ស្កាត់ និងបង្ក្រាបនូវឧបករណ៍នេសាទល្មើសច្បាប់ដែលកំពុងធ្វើការនសាទយ៉ាងអនាធិបតេយ្យ នៅក្នុងបឹងទន្លេសាបយើងនេះ ។

---

**តមកពីទំព័រ ២១**

**ភាពស្មុគ្រស្មាញនៃបញ្ហា...**

នូវអនុក្រិតច្បាប់លេខ ៣៣ នេះផង បើក្នុងតំបន់របស់ពួកគាត់ គឺជាតំបន់ដែលមានជំរៅទឹករាក់ និងដែននេសាទតូចទៀត នេះពិតជាមានការពិបាកក្នុងការធ្វើនេសាទណាស់សំរាប់ប្រជានេសាទនៅក្នុងតំបន់ ហើយបើសិនមានអ្នកវិនិយោគទុនបង្កើតជារោងចក្រ និងឧស្សាហកម្មខ្នាតតូច ឬធំ នៅក្នុងខ័ណ្ឌស្ទឹងហាវ ដើម្បីកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយការនេសាទ និងផ្តល់អោយប្រជាពលរដ្ឋមានការងារធ្វើ ដូចជាស្ត្រី និងកុមារ ។ **តើបញ្ហានេះគួរមានវិធានការណ៍ដោះស្រាយយ៉ាងណាដែរ ?**

# ជីវិតអ្នកនេសាទក្រីក្រផ្ញើរលើព្រលិត និងខ្យង

**អត្ថបទៈ ជិន វុឌ្ឍី**

ធនធានធម្មជាតិបឹងទន្លេសាប បានចិញ្ចឹមជីវិតប្រជាពលរដ្ឋខ្មែររាប់លាននាក់តាំងពីបុរាណកាលរហូតមកដល់ពេលបច្ចុប្បន្ន។ នៅតំបន់បឹងទន្លេសាបមានត្រីរុក្ខជាតិទឹកដូចជា ត្រកួន កញ្ឆែត កំពីងពួយ រំចង់ ច្រាច់ ព្រលិត...។ល។ ដែលប្រជាពលរដ្ឋខ្មែរតែងតែយកមកធ្វើបន្លែសំរាប់ជីវិតរស់នៅរបស់ពួកគេ ។ ប្រជាពលរដ្ឋខ្មែរក្រីក្រនៅជុំវិញតំបន់បឹងទន្លេសាបភាគច្រើនរស់នៅពឹងពាក់យ៉ាងខ្លាំង ដោយបេះរុក្ខជាតិទឹកទាំងនេះធ្វើជារបរប្រចាំថ្ងៃ ដើម្បីជីវភាពរស់នៅរបស់ខ្លួនក្រៅពីការរកនេសាទ ។

បងស្រី **សុន ស៊ិន់** អាយុ ២៩ឆ្នាំ រស់នៅភូមិទី៤ ឃុំចុងឃ្នៀស ស្រុកសៀមរាប ខេត្តសៀមរាប បានប្រកបរបរនេសាទដោយប្រើមងពាក់។ ឆ្នាំមុនៗបងស្រីរកនេសាទត្រីតែក្រោយមកដាក់មងមិនបានត្រី បងស្រីត្រូវបង្វែរមុខរបរមកដកព្រលិតលក់ជារៀងរាល់ថ្ងៃវិញ ដើម្បីចិញ្ចឹមជីវិតកូនទាំងពីរ និងម្តាយចាស់ម្នាក់។ បងស្រីបានបញ្ជាក់ថា "*ត្រីកាន់តែក្រទៅៗ ដោយមានអ្នកឆក់ អ្នកប្រើអ៊ុយស្បៃមុង អ្នកដាក់លបណារ៉ាវ និងឈីបយន្តច្រើន*" ។ បងស្រី ត្រូវធ្វើដំណើរពីផ្ទះទៅកន្លែងដកព្រលិតមានប្រវែងប្រមាណ៤០-៥០ គីឡូម៉ែត្រ ដូច្នេះបងស្រីត្រូវបង្ខំចិត្តក្រោកនៅម៉ោង២រំលងអាធ្រាតដើម្បីធ្វើដំណើរទៅដកព្រលិតដោយអុំកូនទូកដែលជួលពីឈ្មួញនៅក្នុងភូមិ ហើយត្រឡប់មកវិញនៅម៉ោង១:០០ រសៀល ដើម្បីទុកពេលរៀបចំចង និងលក់ព្រលិត ។ ក្នុងមួយថ្ងៃបងស្រីត្រូវ បង់ថ្លៃទូកចំនួន ១០០០រៀល ទៅអោយម្ចាស់ទូក ទោះបីជាចេញទៅបេះព្រលិត ឬមិនទៅបេះក៏ដោយតំលៃនេះត្រូវបង់ជាប្រចាំ ។ នៅពេលមានភ្លៀង ឬខ្យល់ខ្លាំង បងស្រីមិនបានចេញទៅដកព្រលិត ទេតែតំលៃឈ្នួលទូកត្រូវតែបង់អោយទៅម្ចាស់ទូកដដែល។ ក្នុងមួយថ្ងៃបងស្រីបេះព្រលិតបានពី៣០-៦០ដុំ (បាច់) ដែលក្នុងមួយបាច់ៗ ត្រូវចងព្រលិត ២-៣ដើម ហើយក្នុង១បាច់ៗ លក់រាយបានតំលៃ១០០រៀល បើលើកដុំអោយឈ្មួញកណ្តាល១០បាច់ តំលៃ៨០០រៀល។ បងស្រីត្រូវខ្ចីប្រាក់ពីឈ្មួញមុនដើម្បីអង្ករ ប្រាក់បានពីការលក់ព្រលិតត្រូវសងឈ្មួញអស់ក្នុងមួយថ្ងៃៗ ពេលខ្លះ



ថតដោយ : ជិន វុឌ្ឍី

**បងស្រី សុន ស៊ិន់**

មានសល់ប្រាក់តិចតួចបំផុត ។

ចំណូលដែលទទួលបានពីការលក់ព្រលិត បងស្រីត្រូវចំណាយលើការទិញអង្ករ និងថ្នាំពេទ្យ សល់ប្រាក់ខ្លះទុកសំរាប់ចំណាយនៅពេលមានភ្លៀង ឬខ្យល់ខ្លាំងមិនបានចេញទៅរក ។

នៅរដូវប្រាំង បងស្រីរកត្រី មិនបានច្រើនទេដោយប្រើឧបករណ៍ មងពាក់ ក្នុងមួយថ្ងៃចាប់ត្រីបានពី៥-៨គីឡូក្រាម សំរាប់ហូប និងធ្វើប្រហុកខ្លះ សំរាប់ហូបនៅរដូវវស្សា។ ក្នុងករណីរកត្រីមិនបាន បងស្រីបានរកកាប់អុសក្នុងព្រៃដើម្បីលក់ខ្លះ និងដុតខ្លះ។ បងស្រីបានបញ្ជាក់បន្ថែមថា "*ខ្ញុំគ្មាន ជំរើសអ្វីក្រៅពីដកព្រលិត រកត្រី និងកាប់*

*អូសលក់ទេ ព្រោះខ្ញុំធ្លាប់រស់ពឹងពាក់លើធនធានទាំងនេះ* ” ។

បងស្រី **កុំ សុផល** អាយុ ៣០ឆ្នាំ រស់នៅឃុំចុងឃ្មៀសបានអោយ ដឹងថា” *ត្រីឥឡូវនេះក្រណាស់ដាក់មង មិនបានទេព្រោះគ្មានត្រីដោយអ្នកមានដាក់អ៊ុយ លបណារ៉ាវ ទាំងរដូវបិទ និងរដូវបើកនេសាទ ហើយគេបង់លុយអោយទៅអូប៉េ (OP) ប្រចាំការនៅទីនោះ* ” ។ នៅរដូវវស្សា បងស្រីមិនបានរកត្រីទេ បងស្រីបានរកចាប់ខ្យងលក់ដែលធ្វើដំណើរចំងាយប្រមាណ៥០គីឡូម៉ែត្រ ។ បងស្រីចាប់ខ្យងបាន ១៥-២៥គីឡូក្រាមក្នុងមួយថ្ងៃ ហើយ ១គីឡូក្រាមលក់បាន៥០០-៧០០រៀល។ ចំពោះថ្ងៃសៅរ៏ ឬថ្ងៃអាទិត្យ ខ្យងលក់ដាច់ជាងថ្ងៃធម្មតាព្រោះមានភ្ញៀវច្រើន ។ ក្នុងករណីដែលខ្យងលក់មិនដាច់ ខ្យង ១គីឡូក្រាម លក់បានតែ៣០០រៀល ប៉ុណ្ណោះ។ ចំណូលដែលបានមកពីការលក់ខ្យង បងស្រីបានចំណាយសំរាប់ទិញអង្ករ និងឧបត្ថម្ភអោយកូនរៀនដោយបង់ថ្លៃសាលា ២០០រៀលក្នុងមួយថ្ងៃ ។ នៅរដូវប្រាំង បងស្រីបានរកកាប់អុស



ថតដោយ : ជិន វុឌ្ឍី

**បងស្រី កុំ សុផល**

លក់ និងលក់ឪឡឹក ដូច្នេះមុខរបរត្រូវផ្លាស់ប្តូរទៅតាមរដូវ ។ បងស្រីបានបញ្ជាក់បន្ថែមទៀតថា ” *ចាប់ពីពេលនេះទៅមួយជីវិតរបស់គ្រួសារខ្ញុំរស់ដោយពឹងលើខ្យង បើគ្មានខ្យងគ្រួសារខ្ញុំគ្មានជីវិតទេ ព្រោះខ្ញុំក្រណាស់មិនមានលុយទិញសំភារៈដើម្បីរកត្រីអោយបានច្រើនដូចគេ* ” ។ បងស្រីបានជួលកូនទូកពីឈ្មួញផងដែរ ដើម្បីធ្វើដំណើរ ដោយបង់អោយទៅ ម្ចាស់ទូកវិញ ១០០០រៀលក្នុង១ថ្ងៃ ទោះបីបានចេញទៅរក ឬមិនបានចេញទៅក៏ដោយ។ បងស្រី មិនមានជំរើសអ្វីក្រៅពីរបរនេះទេ ព្រោះមុខរបរផ្សេង ត្រូវប្រើដើមទុនច្រើន បើយើងខ្ចីប្រាក់ឈ្មួញលុះត្រាតែមានដី ផ្ទះ កាណូត ទៅបញ្ចាំ ទើប ឈ្មួញអោយលុយខ្ចី ។/

---

**តមកពីទំព័រ ១១**

**បញ្ហាប្រឈមមុខលើការ...**

រដ្ឋាភិបាលមួយចំនួនបានយល់ថា ការជំលៀសប្រជាពលរដ្ឋចេញពីតំបន់មួយទៅរស់នៅក្នុងតំបន់មួយទៀត វាជាការលំបាកក្នុងការផ្លាស់ប្តូរទីតាំងភូមិសាស្ត្រសេដ្ឋកិច្ច ទំនៀមទំលាប់ និងមុខរបរ។ ការធ្វើបែបនេះអាចប្រព្រឹត្តទៅបានលុះត្រាតែការសិក្សាពីតំបន់ថ្មីសំរាប់ប្រជាជនរស់នៅនោះគ្រប់ជ្រុងជ្រោយលើផ្នែកសេដ្ឋកិច្ច វប្បធម៌ សុខមាលភាព សន្តិសុខ និងចំនួនប្រជាពលរដ្ឋដែលអាចរស់នៅក្នុងតំបន់ថ្មីនោះបាន ។ម្យ៉ាងទៀតការជំលៀសប្រជាជនចេញពីតំបន់ពាក់កន្ទេល គួរតែមានសេចក្តីសំរេចពីអភិបាលខេត្ត ឬក្រសួងមហាផ្ទៃជាផ្លូវការសិនមុនពេលធ្វើការងារនេះ ។

ផ្អែកលើគោលនយោបាយកាត់ឡូតិ៍នេសាទរបស់រាជរដ្ឋាភិបាល និងតំរូវការចាំបាច់របស់ប្រជាពលរដ្ឋរស់នៅតំបន់នោះគួរតែត្រូវបានកាត់ដែននេសាទមួយចំនួនសំរាប់ប្រជាពលរដ្ឋ រៀបចំសហគមន៏នេសាទដើម្បីការពារគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព ជាជាងជំលៀសប្រជាពលរដ្ឋចេញពីតំបន់ដែលបានរស់នៅអោយទៅរស់នៅតំបន់ថ្មី ។

# ភាពចំរូងចំរាស់ចំពោះការផ្លាស់ប្តូរតំណែង ប្រធានសហគមន៍ចាស់នៅអន្លង់សំណរ

**អត្ថបទដោយៈ នុំ ធារី**

សហគមមន៍អន្លង់សំណរ ជីក្រែង ជាសហគមន៍នេសាទដែលបានបង្កើតឡើងក្នុងឆ្នាំ ២០០១ ដោយអង្គការស្បៀងអាហារ និងកសិកម្ម (FAO) ប្រចាំខេត្តសៀមរាប ក្រោមការសំរបសំរួលដោយការិយាល័យជលផលនៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។ សហគមន៍នេះមានទីតាំងស្ថិតនៅក្នុង ឃុំអន្លង់សំណរ និងឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប ដែលមានក្រឡាផ្ទៃសរុប ៣៧.៤៣៩ហិចតា និងភូមិចំនួន ៣០ជាសមាជិក ។ ដោយមានកិច្ចជួយជ្រោមជ្រែងពីអង្គការក៏ដូចជាការិយាល័យជលផល ទើបសហគមន៍នេះអាចដំណើរការរហូតមកដល់សព្វថ្ងៃនេះ។ នៅទីនោះ បើទោះជាមានការជ្រោមជ្រែងពីជំនាញជលផលក៏ដោយ ក៏ការចូលរួមនេះនៅមានកំរិតនៅឡើយ ហើយបញ្ហានេះវាជាឧបសគ្គមួយក្នុងការគ្រប់គ្រងអោយមានប្រសិទ្ធិភាព។ ជាក់ស្តែងករណីជំលោះរវាងប្រជារាស្ត្រ និងសហគមន៍នេសាទបានកើតមានឡើងរហូតដល់មានអំពើហឹង្សាមួយ ឈានទៅរកការដុតផ្ទះសហគមន៍ចោល ជាពិសេសការទាមទារសុំអោយដកតំណែងប្រធានសហគមន៍ចាស់ចោល ដោយតំរូវអោយមានការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍សារជាថ្មី ។

ទាក់ទិនទៅនឹងបញ្ហាខាងលើនេះ លោក **ម៉ឿង រស់** អាយុ ៤៧ឆ្នាំ ជាអនុប្រធានសហគមន៍ បានមានប្រសាសន៍ថា នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៤ ខាងជំនាញជលផលបានធ្វើសកម្មភាពកាប់បំផ្លាញឧបករណ៍ខុសច្បាប់មួយចំនួនរួមមាន អ៊ុយ បរ និងលបក្រឡាញឹកដែលរាស្ត្របានដាក់ក្នុងដែនសហគមន៍នៅរដូវបិទនេសាទ ។ ហេតុការណ៍នេះ បានជំរុញអោយប្រជាជនដែលប្រព្រឹត្តបទល្មើសទាំងនោះ មានការខឹងសម្បារយ៉ាងខ្លាំង ដោយសារតែជំនាញបានទទួលលុយពីរាស្ត្រទាំងនោះរួច ហើយដោយ១គ្រួសារ ត្រូវបង់ប្រាក់ពី ២០ទៅ៤០ម៉ឺនរៀល ដែលក្នុងនោះឧបករណ៍តូចក៏ត្រូវបង់យ៉ាងតិច១០ម៉ឺនរៀលដែរ។ ចំពោះបញ្ហា នេះលោកបានបញ្ជាក់ថា ដោយសារតែមានប្រតិកម្មពីរាស្ត្រទាំងនោះ ក្រោយពីការកាប់បំផ្លាញឧបករណ៍ទាំងនោះចោល ទើបខាងជំនាញបានធ្វើការចោទប្រកាន់មកលើសហគមន៍ និងលោកអភិបាលស្រុកដោយធ្វើការអះអាងថា ដោយសារតែខាងសហគមន៍រួមទាំងលោកអភិបាលស្រុកមិនយល់ព្រមសហការទទួលលុយពីអ្នកប្រព្រឹត្តបទល្មើសក្នុងការអនុញ្ញាតិអោយមានការប្រើប្រាស់ឧបករណ៍ល្មើសច្បាប់ ទើបខាងជំនាញត្រូវតែបង្ខំចិត្តធ្វើការបង្ក្រាបឧបករណ៍របស់រាស្ត្រទាំងនេះចោល។ ការញ៉ុះញ៉ង់បែបនេះ បានធ្វើអោយរាស្ត្រទាំងនោះមាន


ថតដោយ : ប៉ែន រង្សី

**លោក ម៉ឿង រស់**

ការខឹងសម្បារយ៉ាងខ្លាំងមកលើសហគមន៍នេសាទ រួមទាំងលោកអភិបាលស្រុកផងដែរ ។ លុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៤ សហគមន៍បានព្យាយាមនឹងធ្វើការដោះស្រាយនូវរាល់ពាក្យចោទប្រកាន់របស់ជំនាញជលផលទាំងនោះ ទៅតាមការស្នើសុំរបស់រាស្ត្រទាំងនោះ ប៉ុន្តែមិនត្រូវបានភាគីខាងរាស្ត្រធ្វើការជួបដោះស្រាយតាមការណាត់ទុកឡើយ ជាពិសេសខាងជំនាញជលផលពុំបានចេញមុខធ្វើការដោះស្រាយជាមួយសហគមន៍ និងលោកអភិបាលស្រុកនូវពាក្យចោទប្រកាន់មកលើសហគមន៍ឡើយ បើទោះជាមានការទាមទារពីសហគមន៍សុំអោយធ្វើការដោះស្រាយនៅចំពោះមុខក៏ដោយ។ រហូតដល់ថ្ងៃទី ១៩ នៅចន្លោះម៉ោងប្រមាណជា ៨:៣០ ទៅម៉ោង ៩:០០ព្រឹក មានអំពើហឹង្សាមួយបានកើតឡើងពីរាស្ត្រទាំង ៦៣ នាក់ ដែលបានចូលរួមក្នុងសកម្មភាពដុតបំផ្លាញផែរបស់សហគមន៍នេសាទចោលរហូតដល់បានសំរេច ។ នៅក្រោយការដុតកំពង់ផែសហគមន៍នេះរួច ភាគីខាងសហគមន៍ក្រោមការជួយអន្តរាគមន៍ពីអង្គការ (FAO) បានធ្វើពាក្យបណ្តឹងទៅនាយកដ្ឋានជលផល ប៉ុន្តែពាក្យបណ្តឹងនេះត្រូវបានអាក់ខានទៅវិញ ដោយសារមានការសំរបសំរួលពីឃុំ ស្រុក សុំអោយមានការដោះស្រាយជាមួយរាស្ត្រទាំង ៦៣នាក់ដោយសន្តិវិធីវិញ។ ក្រោយពីមានការចរចារ ភាគីខាងសហគមន៍បានតំរូវអោយរាស្ត្រទាំងនោះធ្វើការសាងសង់កំពង់ផែជាថ្មីឡើងវិញ ដែលសរុបទឹកប្រាក់ប្រមាណ ១០លានរៀល ។ ការតំរូវអោយមានការសង់កំពង់ផែថ្មីឡើងវិញ ប្រជារាស្ត្រទាំង ៦៣នាក់បានយល់ព្រមសងវិញ ប៉ុន្តែរាស្ត្រទាំងនោះបានដាក់ពាក្យបណ្តឹងទៅខាងជលផល សុំអោយមានការរំលាយសហគមន៍នេះចោល ឬធ្វើការផ្លាស់សមត្ថភាពចាស់ចោល។ ការដាក់ពាក្យបណ្តឹងនេះត្រូវបានខាងជលផលយល់ព្រម ដោយពុំបានធ្វើការពិគ្រោះយោបល់ជាមួយគណៈកម្មការសហគមន៍ឡើយ ដោយសំរេចអោយមានការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ជាថ្មីឡើងវិញ ដែលក្នុងនោះសមាសភាពគណៈកម្មការចាស់នឹងគ្រោងចូលរួមធ្វើជាតំណាងអោយគេបោះឆ្នោតផងដែរ។ ចំពោះការផ្លាស់ប្តូរតំណែងគណៈកម្មការចាស់ចោល **លោក ម៉ឿង រស់** បានមានប្រសាសន៍បន្ថែមទៀតថា ចំពោះការផ្លាស់ប្តូរសមាសភាពគណៈកម្មការសហគមន៍នេះ លោកមិនជំទាស់ប្រឆាំងឡើយ ប៉ុន្តែសុំអោយជំនាញក៏ដូចជារាស្ត្រទាំង ៦៣នាក់នោះស្វែងរកកំហុសរបស់គណៈកម្មការអោយឃើញមុននឹងមានការផ្លាស់ប្តូរតំណែងសហគមន៍ចាស់ចោល។ ចំណុចត្រង់នេះក្នុងនាមជាអនុគណៈកម្មការមិនអស់ចិត្តឡើយ ព្រោះកន្លងមកសមាជិកសហគមន៍យើងបានធ្វើការងារបង្ក្រាបបទល្មើសនេសាទស្ទើរតែគ្មានសល់នៅរាល់រដូវបិទនេសាទម្តងៗ ហើយចំពោះការផ្លាស់ប្តូរនេះសមាជិកសហគមន៍មិនបានគាំទ្រឡើយ។ លោកបានបញ្ជាក់ថា ការផ្លាស់ប្តូរសមាសភាពចាស់ចោល អាចធ្វើអោយសហគមន៍ជួបការលំបាក ដោយសារជនដែលប្រព្រឹត្តបទល្មើសត្រូវបានចូលរួមធ្វើជាគណៈកម្មការ ។ បញ្ហានេះលោកមានការព្រួយបារម្ភជាខ្លាំង បើទោះជាសមាជិកគណៈកម្មការចាស់ត្រូវបានជាប់ឆ្នោតម្តងទៀតក៏ដោយ ប៉ុន្តែវានឹងមានសមាសភាពសមាជិកថ្មីបញ្ចូលនៅក្នុងនោះផងដែរ។

**លោក សាយ ស៊ីថា** អាយុ ៥០ឆ្នាំ ជាហិរញ្ញិកសហគមន៍នេសាទចាស់បានមានប្រសាសន៍ថា " កន្លងមកសហគមន៍បានធ្វើសកម្មភាពជាច្រើន ដូចជាផ្សព្វផ្សាយពីការប្រើប្រាស់ធនធានជលផល និងចុះទៅបង្ក្រាបបទ

**តទៅទំព័រ ២**

# បញ្ហាប្រឈមមុខលើការជំលៀសប្រជាពលរដ្ឋចេញពីភូមិពាក់កន្ទេល ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្ត បាត់ដំបង

**អត្ថបទៈ ជិន វុឡី**

ភូមិពាក់កន្ទេល ជាភូមិមួយស្ថិតនៅក្នុងភូមិសាស្ត្រ ចន្លោះព្រំប្រទល់ឡូតិ៍នេសាទលេខ១នឹងលេខ២ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ ភូមិនេះមានដើមកំណើតក្នុងឆ្នាំ១៩៥៣ ដែលមានប្រជាជនរស់នៅក្នុងសម័យនោះប្រមាណ២០-៣០គ្រួសារ។ ក្នុងរបបគ្រប់គ្រងសម័យប៉ុលពតនៅឆ្នាំ១៩៧៥ ប្រជាជននៅក្នុងភូមិនេះត្រូវបានជំលៀសចេញ។ ចាប់តាំងពីឆ្នាំ១៩៧៩ រហូតមកដល់សព្វថ្ងៃនេះប្រជាពលរដ្ឋបាននាំគ្នាទៅរស់នៅដូចធម្មតាវិញ ដោយប្រកបរបរជាអ្នកនេសាទ ។ នៅពេលបច្ចុប្បន្នមានប្រជាជនចំនួន១៣៥គ្រួសាររស់នៅក្នុងភូមិនេះដែលមិនទាន់បានទទួលស្គាល់ជាផ្លូវការជាភូមិស្របច្បាប់របស់ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជានៅឡើយទេ ទោះបីមានការស្នើសុំរបស់ប្រជាពលរដ្ឋនៅទីនោះ ដើម្បីអោយមានការទទួលស្គាល់ជាភូមិស្របច្បាប់ស្ថិតក្នុងឃុំកោះជីវាំងហើយក៏ដោយ ។ តែទោះជាយ៉ាងណាក្នុងតំបន់ពាក់កន្ទេលមានប្រធានភូមិបណ្តោះអាសន្នដែលជ្រើសតាំងដោយមេឃុំកោះជីវាំងដើម្បីទទួលខុសត្រូវក្នុងភូមិនោះតាំងពីឆ្នាំ១៩៨១-១៩៨២ មកម្លេះ។ លើសពីនេះទៀតភូមិពាក់ កន្ទេលមានសាលារៀនមួយខ្នងដែលមានបីបន្ទប់ ឧបត្ថម្ភដោយអង្គការយូនីសេហ្វ ក្នុងឆ្នាំ ២០០២ ។

យោងតាមលិខិតបញ្ជាបេសកម្មរបស់សាលាខេត្តបាត់ដំបងលេខ៩៦បកចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៤បានចាត់តាំងមន្ត្រីរាជការកងកំលាំងប្រដាប់អាវុធ ដែលដឹកនាំដោយលោក **អៀវ ទៀន់នី** ប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្តបាត់ដំបង បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពី លទ្ធផលដោះស្រាយទំនាស់នៅចំណុចពាក់កន្ទេល ឃុំកោះជីវាំង ស្រុកឯកភ្នំ កាលពីថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៤។ ការផ្សព្វផ្សាយនោះ គឺតំណាងប្រជាពលរដ្ឋនៅចំណុចពាក់កន្ទេលចំនួន៩នាក់ត្រូវបានអនុញ្ញាតិអោយចូលរួមក្នុងការប្រជុំផ្សព្វផ្សាយ តែមិនត្រូវបានអនុញ្ញាតិអោយសួរសំណួរអ្វីឡើយ។ ចំណុចសំខាន់ដែលបានផ្សព្វផ្សាយ គឺគណៈប្រតិភូបានបញ្ជាក់ថាចំណុចពាក់កន្ទេលមិនអនុញ្ញាតិអោយបង្កើតជាភូមិស្របច្បាប់ទេព្រោះបង្កអោយមានផលប៉ះពាល់ដល់ដែនជីវចំរុះ សំរាប់អភិរក្សនឹងការពារធនធានធម្មជាតិ ជាពិសេសពពួកសត្វស្លាបទឹក។ ម្យ៉ាងទៀតចំណុចពាក់កន្ទេលស្ថិតនៅក្នុងឡូតិ៍នេសាទលេខ១នឹងឡូតិ៍លេខ២ ខេត្តបាត់ដំបង។ លើសពីនេះទៅទៀតប្រជាពលរដ្ឋនៅទីនោះចល័តគ្រប់រដូវកាល ។ ក្រៅពីនេះប្រជានេសាទកាន់តែកើនច្រើនឡើងធ្វើអោយរំខានដល់ឡូតិ៍ ពេលខ្លះមានជនខិលខូចមួយចំនួនបានលបលួចចូលទៅរកនេសាទត្រីនៅក្នុងឡូតិ៍ដែលជាហេតុបង្កការលំបាកដល់ម្ចាស់ឡូតិ៍។ គណៈ-ប្រតិភូបានបញ្ជាក់បន្ថែមថា បើប្រជាជនមិនព្រមចេញពីភូមិពាក់កន្ទេលទេ សាលារៀននឹងត្រូវអូសយកទៅដាក់នៅភូមិក្បាលតោល ឬ ភូមិព្រែកទាល់ ។ តែការពិតនៅពេលដែលប្រជាពលរដ្ឋរស់នៅក្បែរឡូតិ៍ ប្រជាជនបានឃើញសកម្មភាពនេសាទ របស់ម្ចាស់ឡូតិ៍ធ្វើផ្ទុយពីសៀវភៅបន្ទុកឡូតិ៍នេសាទនឹងច្បាប់នេសាទ ហើយធ្វើការរាយការណ៍ទៅស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីរកវិធានការទប់ស្កាត់បទល្មើសទាំងនោះ ដូច្នេះហើយម្ចាស់ឡូតិ៍រកលេសដើម្បីជំលៀស

ប្រជាជនចេញពីតំបន់នេះ ដើម្បីងាយស្រួលដល់ពួកគេប្រព្រឹត្តបទល្មើសនេសាទក្នុងដែនឡូតិ៍ ដែលម្ចាស់ឡូតិ៍ទាំងនោះទទួលធ្វើអាជីវកម្ម ។ ជាក់ស្តែងមិនមែនមានតែប្រជាជននៅភូមិពាក់កន្ទេលទេ ដែលរស់នៅចល័តតាមរដូវ កាលនោះសូម្បីតែប្រជាជនដ៏ទៃទៀត ដែលរស់នៅតាមភូមិបណ្តែតទឹកជុំវិញបឹងទន្លេសាប ក៏ត្រូវចល័តដូចគ្នាដែរ ព្រោះនៅរដូវទឹកតំលើងមានខ្យល់ព្យុះ ប្រជាជនត្រូវការទីកន្លែងដែលមានសុវត្ថិភាពសំរាប់ជ្រក ។ លើសពីនេះទៅទៀតមិនមែនមានតែប្រជាពលរដ្ឋនៅភូមិពាក់កន្ទេលទេ ដែលធ្វើអោយប៉ះពាល់ដល់ជីវចំរុះនោះ សូម្បីតែប្រជាជនដែលរស់នៅតាមដងស្ទឹងផ្សេងៗនឹងអ្នក នៅជុំវិញបឹងទន្លេសាបទាំងមូលក៏ធ្វើអោយមានផលប៉ះពាល់ដល់ជីវៈចំរុះដែរ ដោយរួមទាំងម្ចាស់ឡូតិ៍នេសាទផង ។

ទោះជាយ៉ាងណាក៏ដោយ ក៏ប្រជាពលរដ្ឋបានធ្វើសំណូមពរមិនចាកចេញពីតំបន់ពាក់កន្ទេល ដោយពួកគាត់យល់ថាការស់នៅទីនេះមានតាំងពីឆ្នាំ១៩៨៣មកម្ល៉េះ ហើយការរស់នៅទីនេះងាយស្រួលក្នុងការរកនេសាទសំរាប់ជីវភាពរស់នៅរបស់ពួកគាត់ និងតំបន់នេះមិនស្ថិតនៅក្នុងឡូតិ៍នេសាទលេខ១ និងឡូតិ៍លេខ២ទេ ។ ម្យ៉ាងទៀតការបង្កអោយប៉ះពាល់ដល់ដែនជីវសាស្ត្រចំរុះសំរាប់អភិរក្ស និងការពារធនធានធម្មជាតិ នោះមិនមែនប្រជាពលរដ្ឋរស់នៅតំបន់នោះទេតែ បណ្តាលមកពីម្ចាស់ឡូតិ៍នេសាទផងដែរ ព្រោះម្ចាស់ឡូតិ៍តែងរត់ព្រួល លបលាក់វ៉ៃ និងព្រួលក្រឡាញីកចាប់ត្រីផ្ទុយនឹងបទដ្ឋានបច្ចេកទេស ។ នៅរដូវប្រាំងម្ចាស់ឡូតិ៍នេសាទបានឆ្លៀតឱកាសឆក់ត្រីតាមជើងព្រួល និងបូមពង្រឹងតាមបឹង ព្រៃរួចប្រើកម្មករឆក់ត្រីទៀតផង។ តាមពិតមានពីអ្នក-ភូមិពាក់កន្ទេលនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤ លោកប្រធានមន្ទីរទំនាក់ទំនងព្រឹទ្ធសភារដ្ឋសភា និងអធិការកិច្ចខេត្តបាត់ដំបង លោកអភិបាលស្រុកឯកភ្នំ លោកមេឃុំកោះជីវាំង នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំកោះជីវាំងរួមទាំងកងកំលាំងប្រដាប់អាវុធផ្សេងទៀតបានមកធ្វើសកម្មភាពអូសទាញយកសាលារៀនព្រមទាំងឃាត់ខ្លួនលោក **ប៊ិន ផល** ជាគ្រូបង្រៀន និងលោក **ប៊ិន សុខ** ជាមេភូមិបណ្តោះអាសន្នឃុំខ្លួននៅផ្ទះផែម្ចាស់ឡូតិ៍លេខ ២ អស់រយៈពេល២ម៉ោង និង ៣០នាទី ។ កងកំលាំងទាំងនេះមានកាំភ្លើងអាកាចំនួនជាង១០ដើម ។ ដោយមានការតវ៉ាពីប្រជាជននៅទីនោះសាលារៀនមិនត្រូវបានគេទាញចេញពីភូមិនោះទេក្នុងអំឡុងពេលនោះកងកំលាំងប្រដាប់អាវុធបានបើកសោរកាំភ្លើង ហើយអាមេធ្វើអោយសិស្សចំនួន២នាក់ផ្អើលរត់ដួលធ្លាក់បែកក្បាល ។ នៅពេលដែលប្រជាជនធ្វើការតវ៉ាកងកំលាំងប្រដាប់អាវុធទាំងនោះបានធ្វើការគំរាមកំហែងរកដាក់ខ្នោះ និងបាញ់សំលាប់ ។

ក្រោយការទទួលរបាយការណ៍ស្តីពីបញ្ហាភូមិពាក់កន្ទេល និងបទអន្តរាគមន៍របស់អង្គការសម្ព័ន្ធភាព ដើម្បីអភិរក្សធនធានជលផល FACT, អង្គការអភិវឌ្ឍន៍ស្ត្រី(AS) , អង្គការ-ក្រុមទ្រទ្រង់ភូមិ (VSG) និងគណៈកម្មការប្រព្រឹត្តកម្មនៃអង្គការការពារសិទ្ធិមនុស្ស(CDP -LICADH O, AD-HOC -KKKHRA,LAC,Vigilance-KKKHRDA) ប្រចាំខេត្តបាត់ដំបងរួចមក ឯកឧត្តមអភិបាលខេត្តបាត់ដំបងបានធ្វើលិខិតមួយជូនក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ស្នើឱ្យធ្វើការសិក្សាឡើងវិញ នៅភូមិពាក់កន្ទេលដែលមានស្ថាប័នទទួលបន្ទុកការងារនេះ គឺនាយកដ្ឋានជលផល ។ រហូតមកទល់ពេលនេះមិនទាន់ដឹងថា នាយកដ្ឋានជលផលមានគំរោងផែនការបែបណាចំពោះបញ្ហានេះនៅឡើយទេ ។

បើតាមមតិរបស់អង្គការមិនមែន

**តទៅទំព័រ ៧**

# ទូកនេសាទជនជាតិវៀតណាម រាប់រយទូកសប្បាយនឹងការនេសាទត្រីប្រាខ្មៅ

**អត្ថបទដោយ: ស្នួង ពិសិដ្ឋ**

នៅតាមដងទន្លេសាប ចាប់ពីគល់ស្ពានជ្រោយចង្វាត្រើយខាងកើត ក្នុងភូមិសាស្ត្រ ខ័ណ្ឌឬស្សីកែវស្ថិតក្នុងភូមិដើមគរទី១ រហូតទៅដល់ភូមិដើមគរទី៤ ក្នុងសង្កាត់ជ្រោយចង្វា មានទូកនេសាទពពាក់ពពូនគ្នារាប់រយទូកបណ្តែតកណ្តាលទន្លេមើលទៅដាច់កន្ទុយភ្នែក ដែលទូកបណ្តែតនេះត្រូវបានអ្នកភូមិរាយការណ៍ថា ជារបស់ជនជាតិវៀតណាមធ្វើការនេសាទស្ទូចកូនត្រីប្រាខ្មៅ ។ តាមប្រភពពតិមានដដែលនេះបានអោយដឹងថា ទូកវៀត-ណាមទាំងអស់នេះពួកគេកំពុងតែស្ទូចនិងដងកូនត្រីប្រាខ្មៅព្រមទាំងកូនត្រីប្រាធំធម្មតាយ៉ាងសប្បាយដោយគ្មានសមត្ថកិច្ចណាមករារាំង ឬមកទប់ស្កាត់ឡើយ ។

អ្នកភូមិនៅក្នុងតំបន់នោះបានឱ្យដឹងទៀតថា ទូកជនជាតិយួនទាំងអស់នេះបានមកបណ្តែតនៅទីនេះទាំងយប់ទាំងថ្ងៃអស់រយះពេល២ខែមកហើយដើម្បីស្ទូចត្រីប្រាខ្មៅដែលកូនត្រីប្រាខ្មៅទាំងអស់នោះទើបតែមានរូបរាងទំហំប៉ុន១ម្រាមដៃប៉ុណ្ណោះ ។ ពួកទូកនេសាទជនជាតិយួនដែលដងកូនត្រីនិងស្ទូចកូនត្រីនេះបានប្រើឧបករណ៍ដូចជាកញ្ជូនធ្វើពីស្បៃមុងឯចំពោះសន្ទូចវិញគេពត់ដែកអោយមានរាងជាដង្កៀបដូចដងធ្នូមានប្រវែងប្រហែល ១,៥០ម៉ែត្រ រួចគេចងខ្សែធំមួយដោយមានផ្លែសន្ទូចរាប់រយផ្លែ។ ចំណែកនុយដែលគេប្រើគឺកូនសត្វអង្រ្កង និងនុយមួយបែបទៀតគឺជន្លេនសមុទ្រ។ តាមការសាកសួរ និងបំភ្លឺពីពួកទូកនេសាទជនជាតិយួនទាំងនោះដោយផ្ទាល់បានអោយដឹងថានុយអង្រ្កងគឺពួកគេរកនៅតាមដើមឈើនៅក្បែរៗភូមិរបស់អ្នកស្រុកចំណែកឯជន្លេនសមុទ្រវិញគឺពួកគេបានទិញមកពីប្រទេសវៀតណាមក្នុងតំលៃ៤ម៉ឺនរៀលក្នុង១គីឡូក្រាម ។ អ្នកភូមិបាននិយាយទៀតថា នុយជន្លេននេះឱ្យតែបិទនៅលើផ្លែសន្ទូចហើយកូនត្រីប្រាស៊ីភ្លាមគឺស្ទូចបានច្រើនខ្លាំងណាស់ដែលក្នុងមួយថ្ងៃគេអាចស្ទូចបានពី៣០០ទៅ៥០០ក្បាលក្នុង១ទូក ៗ ។ ចំពោះកូនត្រីប្រាដែលពួកគេស្ទូចបានមកនោះមិនពិបាកលក់នោះទេ គឺយប់ឡើងមានម៉ូយមកទទួលទិញដល់ៗ ទូកតែម្តង ហើយក៏មានអ្នកខ្លះយកទៅបន្សាំចិញ្ចឹមដាក់ក្នុងបែរទុករហូតដល់ត្រីប្រាត្រូវប៉ាន់ដែលជាក់ស្តែងនោះគ្មានសមត្ថកិច្ចណាមកមើល ឬមកចាប់នោះឡើយ ។ ក្នុងមួយថ្ងៃៗគេឃើញ



ថតដោយ : ស្នួង ពិសិដ្ឋ

**រូបភាពទូកនេសាទជនជាតិវៀតណាមធ្វើការស្ទូចយកកូនត្រីប្រាខ្មៅនៅក្នុងទន្លេ**

មានទូកចល័តដើរប្រមូលលុយតាមទូក មិនដឹងថាជាទូកសមត្ថកិច្ចរបស់ជលផល ឬក៏ជាទូកសមត្ថកិច្ចណាទេ ហើយក៏មិនដឹងថា ទូកមួយគ្រឿងត្រូវបង់ប្រាក់ចំនួនប៉ុន្មានរៀលដែរឱ្យទៅអ្នក



ថតដោយ : ស្វង ពិសិដ្ឋ

**ការបង្ហាញឧបករណ៍ស្ទូចកូនត្រីប្រាខ្មៅ**

ដើរប្រមូលលុយនោះទេ ។ បញ្ហានេះត្រូវបានអ្នកភូមិនិយាយថា បើទូករបស់ជនជាតិយួនទាំងនោះមិនបង់លុយឱ្យម្ចាស់ទន្លេទេក៏មិនអាចអង្គុយស្ទូចកូនត្រីទាំងយប់ទាំងថ្ងៃបានសុខស្រួលដែរ ។ ម្យ៉ាងវិញទៀតមិនថាតែនៅឆ្នាំនេះទេដែលមានព្រឹត្តិការណ៍នេះកើតមានឡើង សូម្បីតែបណ្ដាឆ្នាំកន្លងទៅក៏មានទូកនេសាទជនជាតិយួនរាប់រយទូកមកធ្វើការនេសាទយ៉ាងអនាធិបតេយ្យដូច្នេះដែរ ហើយក៏គ្មានការអើពើ ឬដឹងឮពីបណ្ដាសមត្ថកិច្ចណាម្នាក់ដែរ ។

ដោយឡែកយោងតាមអត្ថបទចេញផ្សាយដោយកាសែតរស្មីកម្ពុជា ឆ្នាំទី៣៧ លេខ៥២០៩ចុះថ្ងៃ ទី២៦ ខែសីហា ឆ្នាំ ២០០៤ លោក **ណៅ ធួក** ប្រធាននាយកដ្ឋានជលផល បានធ្វើការបំភ្លឺថា ការស្ទូចកូនត្រីប្រានេះមិនខុសច្បាប់ទេមិនថាខ្មែរ ចាម ឬយួន ឡើយ គឺស្ទូចបានមិនមានការហាមឃាត់ទេ ព្រោះកាលពីឆ្នាំ២០០១ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានប្រកាសរួចហើយ ពីការអនុញ្ញាតិជាទូទៅឱ្យប្រជាពលរដ្ឋធ្វើការនេសាទ មិនថានៅទីណានោះទេ។ លោកមានប្រសាសន៍ឱ្យដឹងទៀតថា ជាការពិតនៅមុនឆ្នាំ ២០០១ ការស្ទូចយកកូនត្រីប្រាខ្មៅនេះត្រូវបានចាត់ទុកថា ល្មើសច្បាប់ ប៉ុន្តែច្បាប់នេះមិនអាចរារាំងបានទេ ហើយបង្កអោយមានបញ្ហាចោទជាច្រើន ។ តាមលោក **ណៅ ធួក** បានឱ្យអោយដឹងទៀតថា តាមទំហំត្រី នេះផលរបស់វាមានរាប់រយតោនឯណោះ តែការចាប់ជារៀងរាល់ឆ្នាំមិនបានដល់៥តោនផង ហើយឃើញថាធម្មជាតិរបស់កូនត្រីប្រាខ្មៅនេះមិនបាននៅរហូតឱ្យយើងនេសាទបាននោះឡើយ ប្រសិនបើមិនចាប់យកវាទៅចិញ្ចឹម ។ លោកនាយកដ្ឋានជលផលបានពន្យល់ថា ជាធម្មជាតិនៅរដូវទឹកឡើង ត្រីប្រាបានពងនៅឯផ្នែកខាងលើ ហើយពងវាបានអណ្តែតចុះមក និងបានញាស់នៅពាក់កណ្ដាលខែសីហា។ លោកបានបន្តទៀតថានៅខែតុលាត្រីប្រាខ្មៅនេះ ភាគច្រើនមានដំបៅ ហើយបានងាប់ ហើយចំនួនត្រីដែលបាននៅសល់វាបានធំធាត់រួចឈានមកដល់ផ្ទៃទន្លេប្រទេសវៀតណាម ហើយត្រីនេះវារស់នៅបាតទន្លេឯប្រទេសវៀតណាម។

លោក **ណៅ ធួក** បានមានប្រសាសន៍ថា តាមគន្លងធម្មជាតិរបស់ប្រភេទត្រីប្រានេះវាធំពេញវ័យទៅទន្លេវៀតណាមឯណោះ ឯការពងនិងញាស់កូននៅកម្ពុជា ត្រីប្រាខ្មៅនេះដំបៅ ហើយងាប់បណ្ដើរៗនៅក្នុងខែតុលា ដូច្នេះហើយបើយើងការពារមិនអោយធ្វើការនេសាទនោះ កូនត្រីប្រាខ្មៅនេះនឹងត្រូវងាប់ ហើយសល់ប៉ុន្មានវាហូរចូលទៅក្នុងទន្លេប្រទេសវៀតណាម ដែលនៅខាងក្រោមប្រទេសកម្ពុជាយើង ដូច្នេះផលដែលបានមកពីប្រភេទត្រីនេះមិនធំដុំទេហេតុនេះ ហើយទើបក្រសួងកសិកម្ម បានឯកភាពអោយប្រជាពលរដ្ឋយើងធ្វើការនេសាទជាមុខរបរទៅចុះ ទោះបីជាបែបណាក៏មានការទទួលបានប្រាក់កម្រៃចិញ្ចឹមជីវិតគ្រប់គ្នាដែរ ពិសេសប្រជាពលរដ្ឋក្រីក្រ ។លោកក៏មានប្រតិកម្មដែរចំពោះ

មជ្ឈដ្ឋានខ្លះបានចោទថា សមត្ថកិច្ចជលផលមិនអើពើមិនទប់ស្កាត់ការ ស្ទូចយកកូនត្រីប្រាខ្មៅនេះដែលការពិតការនេសាទនេះមិនខុសច្បាប់ទេ ។

ទោះបីជាបែបណាតាមប្រសាសន៍មន្ត្រីខាងលើដែលថា មិនខុសច្បាប់នេះគឺហាក់ដូចជាហុចឱកាសមួយអោយទូកអ្នកនេសាទយួនបានដៃ និងមានឱកាសធ្វើការនេសាទពេញទន្លេដែលអ្នកនេសាទខ្មែរមិនអាចទៅនេសាទបានសោះឡើយ។ ដែលនេះវាខុសពីការផ្តល់លទ្ធភាពអោយអ្នកនេសាទខ្មែរអាចរកកម្រៃបានពីការស្ទូចកូនត្រីប្រាខ្មៅនេះបែរជាឃើញតែក្រុមអ្នកនេសាទសុទ្ធតែយួន។ ខ្មែរក្រីក្រច្រើនណាស់ពេលមានឱកាសរកបែរជាអត់ឃើញទៅវិញ ពិតជាគួរអោយសោកស្តាយណាស់។

---

**តមកពីទំព័រ ២៤**

**អ្នកភូមិអន់ធ្លើតមានសង្ឃឹម......**

នេះបានឱ្យដឹងថា " ពេលមុននៅពេលដែលប្អូនគាត់ចេញទៅនេសាទម្តងៗ គាត់មានការភ័យខ្លាចយ៉ាងខ្លាំងដោយខ្លាចជួបជាមួយពួកអ្នកនេសាទដែលប្រើទូកអូស ទូកឌុន (ពួកនេសាទប្រើឧបករណ៍ខុសច្បាប់) ព្រោះថានៅពេលដែលជួបជាមួយពួកទាំងនោះគាត់ខ្លាចពួកគេបុកពន្លិចទូក ឬវាយតប់ប្អូនរបស់គាត់ជាដើម ។ គាត់បានបន្ថែមទៀតថា " ការនេសាទសព្វថ្ងៃនេះវាមានការជួបលំបាកយ៉ាងខ្លាំងដោយសារទូកអូស ទូកឌុនដែលការនេសាទរបស់ពួកគេទាំងនោះបានធ្វើអោយប៉ះពាល់ដល់មងបង្គាដែលជាហេតុធ្វើអោយរហែកនឹងពេលខ្លះត្រូវពួកទាំងនោះបានសារយកទៅទៀត ។ ផ្ទុយទៅវិញបន្ទាប់ពីសហគមន៍នេសាទតំបន់ឆ្នេរកោះខ្យងត្រូវបានបង្កើតឡើង គាត់បានសង្កេតឃើញថាអំពើទាំងនេះមានការថយចុះគួរអោយកត់សំគាល់ដែលធ្វើឱ្យគាត់មានការសប្បាយរីករាយយ៉ាងខ្លាំង ។

ជារួមការបង្កើតសហគមន៍នេះបានផ្តល់សារៈសំខាន់យ៉ាងខ្លាំង ព្រោះនេះគឺជាជំនាក់កាលដំបូងមួយនៃការសាកល្បង (សហគមន៍តំបន់ឆ្នេរ) ដើម្បីលើកស្ទួយជីវភាពប្រជាជន ក៏ដូចជាការពារធនធានធម្មជាតិនៅតំបន់មូលដ្ឋានអោយមានលក្ខណៈនិរន្តភាពដែលបានបង្ហាញនូវការរីកដុះដាល នៃការគ្រប់គ្រងតាមបែបវិមជ្ឈការនៅក្នុងប្រទេស ។

---

**តមកពីទំព័រ ១៦**

**តំបន់អភិរក្សធនធានមច្ឆាជាតិ..**

ចូលរួមចំណែកអភិរក្សធនធានមច្ឆាជាតិ ។

នៅពេលបច្ចុប្បន្នពេលតំបន់នេះបានធ្វើអោយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដល់សាធារណៈជន រហូតដល់ក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការអន្តរជាតិដ៏ទៃទៀតបានទៅធ្វើទស្សនៈកិច្ចសិក្សានៅតំបន់នេះ ហើយបានចាត់ទុកតំបន់នេះជាគំរូអភិរក្សដ៏ល្អមួយ។

# តំបន់អភិរក្សធនធានមច្ឆាជាតិ ភូមិព្រែកត្រប់ ឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ កំពុងធ្វើអោយមានការភ្ញាក់ផ្អើលដល់សធារណៈជន

**អត្ថបទ: ជិន វុឡី**

ភូមិព្រែកត្រប់ជាភូមិមួយមានចំងាយប្រមាណ១៨គីឡូម៉ែត្រ ខាងជើងពីទីក្រុងបាត់ដំបង ស្ថិតនៅក្នុងឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ។ នៅក្នុងភូមិនេះមានវត្តមួយកំពុងសាងសង់មិនទាន់ចប់សព្វគ្រប់នៅឡើយ ។ នៅក្នុងឆ្នាំ១៩៩៥ ព្រះចៅអធិការវត្តរួមនឹងប្រជាជនរស់នៅក្បែរវត្តបានមូលមតិគ្នាជីកស្រះមួយដែលមានបណ្តោយ ៧០ម៉ែត្រ និងទទឹង ៣០ម៉ែត្រ ជំរៅ ៤ ម៉ែត្រ ដើម្បីយកអាចម៍ដីមកចាក់ទីទួលសំរាប់សង់ព្រះវិហារ ។ នៅរដូវវស្សាទឹកជន់បានចូលលិចស្រះធ្វើអោយត្រីធម្មជាតិចូលពេលទឹកស្រក ត្រីមិនបានចាកចេញពីស្រះនោះទេធ្វើអោយត្រីកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។

លោក **សេង យី** ប្រធាន-ក្រុមប្រឹក្សាឃុំព្រែកនរិន្ទ បានមានប្រសាសន៍ថា " ស្រះនេះបានកើតឡើងក្នុងឆ្នាំ ១៩៩៥ ហើយត្រីធម្មជាតិបានចូលមករស់នៅ។ ព្រះសង្ឃ និងគណៈកម្មការវត្តបានយកចិត្តទុកដាក់ការពារត្រីមិនអោយចេញព្រោះយល់ថាវាជាសម្បត្តិរបស់វត្ត។ បច្ចុប្បន្នត្រីក្នុងស្រះនេះមានប្រមាណជា ១០ តោន ដោយត្រីឆ្តោរ១ក្បាលដែលធំជាងគេនៅទីនោះមានទំងន់ប្រមាណ ២០គីឡូក្រាម ទៅ២៥គីឡូក្រាម រហូតដល់ប្រជាជននៅក្នុងភូមិនោះដាក់



ថតដោយ : ជិន វុឡី

**លោក សេង យី**

ឈ្មោះថា ត្រីរាហ៊ូ " ។ ដោយជំរៅទឹកជ្រៅនៅរដូវវស្សាត្រីមិនចេញទៅណាឆ្ងាយពីទីនេះទេពេលរដូវទឹកស្រក ត្រីដែលធ្លាប់នៅក្នុងស្រះត្រូវចូលមករស់នៅក្នុងស្រះដដែល ។ លោកក្រុមប្រឹក្សាឃុំបានបន្តទៀតថា " ត្រីទាំងអស់ដែលរស់នៅក្នុងស្រះនេះមិនមានអ្នកណាលួចទេដោយគេយល់ទាំងអស់គ្នាថា វាជាទ្រព្យសម្បត្តិរបស់យើងទាំងអស់គ្នា ។ម្យ៉ាងទៀតប្រជាជននៅទីនោះតែងយល់ថា ត្រីនៅក្នុងវត្តវាជាទ្រព្យសម្បត្តិរួមនៅក្នុងវត្តមិនមានអ្នកណាហ៊ានលួចផ្តេសផ្តាសទេ។ លើសពីនេះប្រជាជនទាំងនោះបានសហការជាមួយព្រះសង្ឃ ដើម្បីជួយយាមនៅពេលយប់ការពារខ្លាចមានអ្នកផ្សេងលួចចាប់ត្រី " ។

លោក **ឈឹម ប៊ូរី** អាយុ ៣០ឆ្នាំ ជាប្រជាជនរស់នៅភូមិជ្រៃ ឃុំ រូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង បានមកចិញ្ចឹមទានៅក្បែរតំបន់នោះ បានបញ្ជាក់អោយដឹងថា " ត្រីនៅក្នុងស្រះនេះធំៗ ណាស់មិនមានប្រជាជនណាហ៊ានចូលរកទេដោយប្រជាជននៅទីនេះយល់ថា វាជាទ្រព្យសម្បត្តិរបស់វត្ត ហើយព្រះសង្ឃការពារត្រីនេះទុកសំរាប់កូនចៅជំនាន់ក្រោយ និងសំរាប់បន្តពូជ " ។ នៅពេលរដូវទឹកឡើងត្រីវាចេញស្រេចតែចិត្តរបស់វា ព្រះ



ថតដោយ : ជិន វុឡី

**ឈឹម ប៊ូរី**

សង្ឃមិនរារាំងវាទេ តាមពិតវាមិនទៅណាឆ្ងាយពីស្រះនោះទេព្រោះនៅពេល

ទឹកស្រកគេឃើញ ត្រីមករស់នៅក្នុងស្រះនេះដដែលហើយមានចំនួនច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ។

អ្នកមីង **អួត ពៅ** អាយុ ៤៨ឆ្នាំ ជាប្រជាជនរស់នៅភូមិព្រៃក គ្រប់ ឃុំព្រៃកនិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបងបានបញ្ជាក់ថា " ប្រជាជននៅទីនេះមានការសប្បាយចិត្តយ៉ាងខ្លាំង ដោយឃើញព្រះសង្ឃជួយការពារត្រីយ៉ាងនេះ។ មានប្រជាជនមកពីចំងាយមកលួចរកនៅក្នុងស្រះនេះដែរតែរក



បិតដោយ : ជិន វុឌ្ឍី

**អ្នកមីង អួត ពៅ**

មិនបានទេដោយព្រះសង្ឃ និងប្រជាជនក្នុងភូមិនោះរួមគ្នាការពារ។អ្នកមីងបានបញ្ជាក់ទៀតថា នៅរដូវវស្សាមានត្រីឆ្តោរខ្លះដេញមនុស្សអុំទូក តែប្រជាជនមិនហ៊ានសំលាប់ត្រីនោះទេដោយគេយល់ថាជាត្រីរបស់វត្ត។ រីឯនៅរដូវប្រាំង ពេលព្រះសង្ឃចុះក្នុងទឹកស្រះដោយមិនប្រុងប្រយ័ត្ន ត្រីឆ្តោរដេញខាំធ្វើអោយព្រះសង្ឃក្នុងវត្តព្រៃកគ្រប់នោះមិនហានចុះផ្តេសផ្តាសទេ ។ អ្នកមីងបានបញ្ជាក់ទៀតថា បើចង់ឃើញត្រីទាំងនេះអោយបានច្បាស់ហើយឃើញត្រីច្រើននោះ អាចមកមើលបាននៅខែ កត្តិក និងមិគសិរ (ខែធ្នូ-មករា) ។ នៅរដូវប្រាំងឆ្នាំនេះ (២០០៤) ត្រីងាប់ច្រើន ដោយទឹកស្អុយ និងក្តៅខ្លាំងពេក ហើយបញ្ចូលទឹកមិនទាន់នៅរដូវប្រាំងគេឃើញមានឆ្អឹងគរច្រើននៅបាតស្រះ ។

នៅពេលបច្ចុប្បន្នស្រះនេះត្រូវបានដាក់បញ្ចូលជាតំបន់អភិរក្សមច្ឆាជាតិ ដោយលើកផ្លាកសញ្ញា ដើម្បីសំគាល់ ។ អង្គការក្រុមអភិវឌ្ឍន៍ភូមិបានជួយឧបត្ថមថវិ ការជាង១០ម៉ឺនរៀល ក្នុងការជួយធ្វើ ផ្លាកសញ្ញាដោយដាក់ឈ្មោះថា " តំបន់អភិរក្សធនធានមច្ឆាជាតិ ភូមិព្រៃកគ្រប់ ឃុំព្រៃកនិន្ទ ស្រុកឯកភ្នំ "ដោយមានការជួយជ្រោមជ្រែងពីក្រុមប្រឹក្សាឃុំព្រៃកនិន្ទ ព្រះសង្ឃ និងប្រជាពលរដ្ឋនៅទីនោះ ។ សូម្បីតែក្មេងក្នុងភូមិក៏ដឹងដែរថា ស្រះនេះគឺជាស្រះអភិរក្សធនធានត្រីមានត្រីធំៗជាច្រើននៅក្នុងស្រះនេះភាគច្រើនសម្បូរត្រីរ៉ស់ ត្រីឆ្តោរ និងត្រីអណ្តែង។ ក្មេងៗនៅក្នុងតំបន់នោះ បានបញ្ជាក់ថា " ពេលភ្លៀងម្តងៗត្រីទាំងនេះលោតចេញពីស្រះឡើងកកតែលោតមិនរួចដោយសងខាងស្រះនោះគោកមានត្រីខ្លះលោតផុតពីមាត់ស្រះមកលើគោកពួកខ្ញុំ (ក្មេងៗ) និងព្រះសង្ឃនៅវត្តនេះបានចាប់ត្រីដាក់ក្នុងស្រះវិញ ប្រជាជននៅភូមិនេះមិនហានចាប់ត្រីនៅក្នុងស្រះនេះទេ ព្រោះអីត្រីនេះជារបស់វត្តដោយព្រះសង្ឃទុកវាអោយធំ ពេលទឹកជន់មក ត្រីខ្លះវាចេញទៅតាមវាលពេលទឹកស្រកវាត្រឡប់មកចូលស្រះវិញ " ។

ក្រុមប្រឹក្សាឃុំ ព្រះសង្ឃ និងប្រជាជនមានគំរោងនឹងអំពាវនាវដល់រាជរដ្ឋាភិបាល សប្បុរសជន អង្គការមិនមែនរដ្ឋាភិបាល ដើម្បីប្រមូលថវិការទិញបង្គោលរបង និងធ្វើការដាំកូនឈើ ដើម្បីផ្តល់ម្លប់ដល់ត្រីនៅក្នុងស្រះនោះ និងធ្វើការពង្រីកស្រះបន្ថែមទៀត ដើម្បីអោយត្រីរស់នៅទូលាយជាងមុន ។

នេះគឺជាគំរូដ៏ល្អមួយរបស់ក្រុមប្រឹក្សាឃុំព្រៃកនិន្ទ ព្រះចៅអធិការវត្តព្រៃកគ្រប់ និងប្រជាជននៅទីនោះដែលមានគំនិតអភិរក្សមច្ឆាជាតិក្នុងតំបន់របស់ខ្លួនដើម្បីជីវភាពរស់នៅ និងដើម្បីកូនចៅជំនាន់ក្រោយ ។ គំរូនេះនឹងត្រូវធ្វើការផ្សព្វផ្សាយជាគំរូល្អដល់ព្រះសង្ឃ និងប្រជាជនដ៏ទៃទៀតដើម្បី

**តទៅទំព័រ ១៤**

# ជីវិតសត្វស្លាបទឹកក្នុងខេត្តកំពង់ធំ កំពុងទទួលរងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ

**នៅខេត្តកំពង់ធំមានសត្វបក្សីទឹកជាច្រើនប្រភេទរួមទាំងសត្វដែលកំរផងដែរ កំពុងទទួលរងនូវការចាប់បំផ្លាញជាទំងន់ ដោយការបំពុល វាយលុប អន្ទាក់ ប្រើកៃវន្លះ និងប្រើបង្កៃ...... ។**

**អត្ថបទៈ ឯម ចន្ទ័ណារិទ្ធ**

ខេត្តកំពង់ធំ គឺជាខេត្តមួយស្ថិតនៅភូមិភាគឧត្តរនៃប្រទេសកម្ពុជា ដែលមានចម្ងាយ១៦៨គីឡូម៉ែត្រពីរាជធានីភ្នំពេញ ដែលក្នុងនោះផ្ទៃដីព្រៃលិចទឹកនៅសល់ប្រមាណ ៨៤៣៣៥ ហិកតាប៉ុណ្ណោះ ក្នុងអំឡុងឆ្នាំ ១៩៩៦-១៩៩៧ (ឯកសារសិក្សាស្រាវជ្រាវរបស់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ)។ ខេត្តកំពុងធំ គឺជាខេត្តមួយក្នុងចំណោមខេត្តទាំង៥ ដែលមានព្រំប្រទល់ជាប់នឹងបឹងទន្លេសាប។ បើផ្អែកទៅលើទីតាំងភូមិសាស្ត្រខេត្តកំពង់ធំមានលក្ខណៈអំណោយផលដោយសារសំបូរទៅដោយប្រភពធនធានធម្មជាតិទាំងក្នុងទឹក និងលើគោក ។



ថតដោយ : ឯម ច័ន្ទណារិទ្ធ

**កូនសត្វខ្សឹបញី**

យោងតាមឯកសារសត្វស្លាបទឹកនៅបឹងទន្លេសាប ត្រូវបានគេកត់ត្រាថាមានប្រមាណ ២០០ប្រភេទ ហើយក្នុងចំណោមសត្វស្លាបទឹកទាំងនោះមានប្រភេទសត្វស្លាបមួយចំនួនកំពុងឋិតនៅក្នុងប្រភេទទទួលរងការគំរាមកំហែងដែលពិភពលោកកំពុងតែព្រួយបារម្ភ និងហាមឃាត់មិនអោយចាប់សត្វទាំងនោះធ្វើអាជីវកម្ម និងបរិភោគ ដូចជាៈ សត្វពពូលទឹក, អកត្រីក្បាលប្រផេះ, ស្មោញ, ត្រយ៉ងខ្លួនស, ត្រយ៉ងខ្លួនខ្មៅ, រនាលស, រនាលពណិ, អង្កត់ខ្មៅ, ត្រដក់តូច, ត្រដក់ធំ, ក្រៀល, ទុង ជាពិសេសសត្វខ្សឹប ( Bengal Florican) ដែលរស់នៅក្នុងខេត្តកំពង់ធំ។ ទាក់ទងនឹងវិធីសាស្ត្រនៃការចាប់ប្រភេទសត្វស្លាបទាំងនោះ បើតាមការសង្កេតយើងឃើញថា មានវិធីសាស្ត្រប្លែកៗ ដែលគេបានអនុវត្តដើម្បីចាប់សត្វស្លាប រួមមានការប្រើប្រាស់ឧបករណ៍ខ្សែអាត់សំលេងសត្វ និងវាយលុបធ្វើពីស្បៃមុង, ការដាក់ថ្នាំបំពុលសត្វ, ការប្រើឧបករណ៍អន្ទាក់, ការប្រើកៃវន្លះ និងការប្រើបង្កៃសន្ទូច។ សកម្មភាពទាំងនោះបានធ្វើអោយប្រភេទសត្វស្លាបទាំងនោះទទួលរងការគំរាមកំហែងមួយយ៉ាងធ្ងន់ធ្ងរ តួយ៉ាងសត្វស្លាបទឹកដែលរស់នៅបឹងទន្លេសាបនាពេលបច្ចុប្បន្ន។ ជាក់ស្តែងនៅក្នុងឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ នៅក្នុងខែសីហា-កញ្ញានេះ មានសកម្មភាពចាប់សត្វស្លាបទឹកមួយចំនួនដូចជា សត្វទោម (Amauromisphoenicurus), សត្វទាព្រៃ (Anas acuta), សត្វខ្វែកត្រោក (Capella gallinago), សត្វក្លុំ ( Fu-

lica atra ) ជាពិសេសគឺខ្សឹប ( Bengal Floricam) ដែលចាប់បានចំនួន ៧ក្បាលក្នុងរវាងពី២ខែនេះ (តាមប្រសាសន៍របស់លោក **លីកាណារ៉ា** អនុ



ថតដោយ : ឯម ប័ន្ណារិទ្ធ

**លោក លីកាណារ៉ា កំពុងកាន់សត្វខ្សឹប**

ប្រធានការិយាល័យអភិរក្សធនធាននៅមន្ទីរបរិស្ថានខេត្តបានអោយដឹងថាសត្វខ្សឹបគឺជា ប្រភេទសត្វដ៏កំរមាន ហើយប្រភេទសត្វនេះមានរស់នៅតែបីប្រទេសប៉ុណ្ណោះនៅលើពិភពលោកគឺ ប្រទេសនេប៉ាល់, ប្រទេសឥណ្ឌា និង ប្រទេសកម្ពុជា ។ ដោយឡែកនៅ ខេត្តកំពង់ធំសត្វខ្សឹបតែងរស់នៅត្រង់ចំណុចឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ។ បើទោះជាមានការហាមឃាត់ពីមន្ត្រីមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន និងការអប់រំផ្សព្វផ្សាយពីអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ក៏ដោយ ក៏បទល្មើសដែលទាក់ទងនឹងការចាប់សត្វស្លាបធ្វើអាជីវកម្ម និងបរិភោគនៅតែកើតមានឡើង ។

អ្នកមីងជាអាជីវករម្នាក់ដោយសុំមិនបញ្ចេញឈ្មោះដែលជាអ្នកចាំទទួលទិញសត្វស្លាបទីកផ្សារកំពង់ធំបានមានប្រសាសន៍ថា " គាត់ជាអតីតអាជីវករម្នាក់លក់ត្រីតាំងពីដើម ក៏ប៉ុន្តែឥឡូវម៉ូយត្រីរកត្រីមកលក់អោយគាត់បានតិចតួចពេក ដូច្នេះគាត់ត្រូវបង្ខំចិត្តទទួលសត្វយកមកលក់ជំនួសវិញ ដើម្បីបន្តមុខរបរតទៅទៀត ជាពិសេសដើម្បីគួបផ្សំរកលុយអោយកូនទៅរៀន។ គាត់បានមានប្រសាសន៍បន្ថែមទៀតថា អ្នកដែលយកសត្វទាំងនេះមកលក់ គឺជាប្រជាជនក្រីក្រដែលពឹងផ្អែកលើការធ្វើស្រែជាចំបង ហើយនៅរវាង ៣ឆ្នាំកន្លងទៅនេះ មុខរបរធ្វើស្រែមិនអំណោយ ផលដល់ពួកគាត់ឡើយ ដែលធ្វើអោយពួកគាត់ត្រូវប្រឈមមុខនឹងការខ្វះស្បៀងអាហារ ហើយកត្តានេះដែលរុញអោយការចាប់សត្វកាន់តែកើនឡើង។ គាត់បានបញ្ជាក់ថា ប្រជាជនទាំងនោះដែលតែងយកសត្វមកលក់ភាគច្រើនមកពីភូមិរកា, ភូមិកំរ៉ែង, ភូមិចំបក់, ភូមិម្នាវ និងភូមិពោធិតាអ៊ុន ដែលឋិតនៅក្នុងឃុំស្រយ៉ូវ និងឃុំកំពង់គោ ។

លោក **ជា សាញ់** ប្រធានសហគមន៍នេសាទភូមិពុកយុក ឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ បានមានប្រសាសន៍ថា វិធីសាស្ត្រមួយដែលសាមញ្ញជាងគេក្នុងចំណោមវិធីសាស្ត្រដ៏ទៃទៀត គឺជនល្មើសបានប្រើប្រាស់ថ្នាំពុលលាយ នឹងចំណីដើម្បីអោយសត្វស៊ី។ លោកបានបន្តទៀតថាកន្លងមកគណៈកម្មការសហគមន៍នេសាទ និងរូបលោកផ្ទាល់បានចុះទៅអប់រំ និងផ្សព្វផ្សាយដល់ប្រជានេសាទក៏ដូចជាសហគមន៍ស្តីពីការអភិរក្សធនធានធម្មជាតិ និងពន្យល់ច្បាប់ដល់ពួកគាត់ ប៉ុន្តែសកម្មភាពបទល្មើសនៅតែកើតមានឡើងជាហូរហែរ ។



ថតដោយ : ឯម ប័ន្ណារិទ្ធ

**សត្វទោចដែលត្រូវគេបំពងជំនួសត្រីដែលកំពុងធ្លាក់ចុះ**

លោក **លី កាណារ៉ា** បានអោយដឹងបន្ថែមទៀតថា លោកបានចុះផ្សព្វផ្សាយច្បាប់ និងសហការជាមួយអាជ្ញាធរមូលដ្ឋានជាពិសេសសហគមន៍ ប៉ុន្តែយើងសង្កេតឃើញថា ការចាប់

តទៅទំព័រ ២៣

# ភាពស្មុគ្រស្មាញនៃបញ្ហានេសាទសមុទ្រ និងផលវិបាក ដល់ជីវភាពប្រចាំថ្ងៃរបស់អ្នកស្ទឹងហាវ

**ត្រីគឺជាអាហារដ៏សំខាន់ទីពីរបន្ទាប់ពីស្រូវដែលបានផ្តល់ប្រូតេអ៊ីនដល់ទៅ ៨០ភាគរយសំរាប់ប្រជារាស្ត្រកម្ពុជា ហើយក៏ផ្តល់ផងដែរនូវសន្តិសុខស្បៀង និងសេដ្ឋកិច្ចសង្គម ។ ប៉ុន្តែបច្ចុប្បន្ននេះធនធានជលផលទាំងនោះកំពុង និងទទួលរងនូវការគំរាមកំហែងឈានទៅរកការវិនាសបាត់បង់ជាបន្តបន្ទាប់ប្រសិនបើគ្មានការទប់ស្កាត់ណាមួយនោះទេ ។ ការគំរាមកំហែងទាំងនោះក៏បាន និងកំពុងនាំមកនូវជំលោះជាច្រើនដែលតែងតែកើតមានឡើងនៅស្ទើរគ្រប់តំបន់នេសាទ មិនថាការនេសាទនៅតំបន់ទឹកសាប ឬ ទឹកប្រៃនៃព្រះរាជាណាចក្រកម្ពុជានោះទេ ។**

**អត្ថបទៈ ឈឹម សោភ័ក្រ**

សង្កាត់ទំនប់រលក ស្ថិតនៅក្នុងខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ដែលមានព្រំប្រទល់ខាងជើងជាប់សមុទ្រ ខាងលិចជាប់សង្កាត់កំពេញ ខាងកើតទល់នឹងខណ្ឌព្រៃនប់ និងខាងត្បូងជាប់សង្កាត់អូរត្រេះដែលមានចំងាយពីក្រុងព្រះសីហនុប្រហែល ២៦គីឡូម៉ែត្រ ។ ប្រជាជនដែលរស់នៅក្នុងសង្កាត់នេះមានចំនួន ១៤៥៦ គ្រួសារ មានចំនួនមនុស្សសរុប ៧៨៦៨នាក់ ក្នុងនោះមានស្រី៣៩១១នាក់ និងប្រុស ៣៩៥៧នាក់ ។

លោក **ហ៊ីង វណ្ណៈ** ជាចៅសង្កាត់ទំនប់រលក បានមានប្រសាសន៍ថា " គណៈកម្មាធិការប្រជាជនបដិវត្តន៍ក្រុងបានផ្ទេរអ្នកនេសាទពីខណ្ឌមិត្តភាពក្រុងព្រះសីហនុអោយមករស់នៅទាំងបីសង្កាត់ គឺសង្កាត់ទំនប់រលកចាស់ សង្កាត់កំពេញចាស់ សង្កាត់អូរត្រេះចាស់ កាលពីឆ្នាំ១៩៨៤ " ។ គាត់បានបញ្ជាក់បន្ថែមទៀតថា " នៅក្នុងខណ្ឌស្ទឹងហាវនេះជាតំបន់ដែលធ្វើការនេសាទ



ថតដោយ : ឈឹម សុភ័ក្រ

**លោក ហ៊ីង វណ្ណៈ**

ខុសនឹងអនុក្រិតច្បាប់លេខ ៣៣ ដែលរាជរដ្ឋាភិបាលចេញមិនអោយធ្វើការនេសាទដែលមានជំរៅទឹករាក់ចាប់ពី ១៥ទៅ២០ម៉ែត្រចុះ " ។ គាត់ក៏បានបន្តទៀតថា " ពីព្រោះនៅក្នុងតំបន់នេសាទរបស់ពួកគាត់គឺជាតំបន់ដែលមានជំរៅទឹករាក់ចាប់ពី១៥ទៅ២០ម៉ែត្រ ហើយប្រជាជនដែលរស់ក្នុងខ័ណ្ឌស្ទឹងហាវនេះដែលប្រកបមុខរបរធ្វើនេសាទវាមានផលលំបាកយ៉ាងខ្លាំងម្យ៉ាងទៀត តំបន់នេសាទរបស់ពួកគាត់ មានដែននេសាទតូចថែមទៀត ។ បើពួកគាត់ចង់ទៅធ្វើការនេសាទដែលមានជំរៅទឹកចាប់ពី ២៥ម៉ែត្រឡើងទៅ ពួកគាត់គ្មានទូកធំៗដើម្បីធ្វើការនេសាទនោះទេ ដោយសារគ្មានលុយទិញ រឺធ្វើទូកធំទាំងនោះ ។

លោក **តាំង ស្រេង** ជាចៅសង្កាត់រងទី១ បានមានប្រសាសន៍ផងដែរថា " សព្វថ្ងៃនេះអ្នកនេសាទក្នុងខ័ណ្ឌស្ទឹងហាវដែលមានទូកតូចៗសំរាប់

អួសក្តាម អួសបង្គា រកនេសាទមិនបាន ផង ហើយត្រូវបានទទួលរងការគំរាម កំហែង និងគាបសង្កត់ពីសំណាក់អស់ លោកសមត្ថកិច្ចជំនាញ និងសហគមន៍ នេសាទដែលមានទីតាំងនៅតំបន់អន់-ឆ្អើត តាបែន និងតំបន់កោះខ្យង ស្រុក ស្រែអំបិលនេះស្ទើររាល់ថ្ងៃសឹងតែមិន អាចចេញទូកធ្វើការនេសាទទៅបាន"។ គាត់បានបន្ថែមទៀតថា "ទោះបីជាអ្នក នេសាទនៅក្នុងខណ្ឌស្ទឹងហាវបានគោរព ច្បាប់មិនចូលទៅនេសាទក្នុងដែនសហ គមន៍របស់ពួកគេកាន់កាប់យ៉ាងណាក៏ ដោយ ក៏ពួកគេអាចចេញមកចាប់ យកទូករបស់ពួកគាត់យកទៅផាក វិន័យដែរ បើសហគមន៍ចាប់ទូកត្រូវ បង់ជាប្រាក់អោយសហគមន៍របូត ទៅដល់៤០០០បាត (៤០ម៉ឺន រៀល) ក្នុងមួយទូក ហើយបើសមត្ថកិច្ចចាប់ វិញម្ចាស់ទូកត្រូវបង់ប្រាក់ ២០០០បាត (២០ម៉ឺនរៀល) តិចជាងសហគមន៍។ ដូច្នេះអំពើរបស់អ្នកដែលមានអំណាច ទាំងនេះ ហើយបានជាធ្វើអោយប្រជា-នេសាទនៅតំបន់ខ័ណ្ឌស្ទឹងហាវមានការ ខ្វះខាតក្នុងការចិញ្ចឹមជីវិតដោយធ្វើការ នេសាទរកត្រី បង្គាមិនបានជាពិសេស ទៅទៀតត្រូវបានជំពាក់លុយពីធនាគារ និងអ្នកដង្ហៅដែលបានអោយខ្ចីលុយ សំរាប់ទៅធ្វើការនេសាទ"។

តាមសម្តីរបស់ប្រជានេសាទមួយ ចំនួនដែលរស់នៅក្នុងខ័ណ្ឌស្ទឹងហាវបាន ជួយបញ្ចេញមតិដូចគ្នាថា "ការធ្វើនេ-សាទរបស់ពួកគាត់ទាំងអស់គ្នាមាន ការជួបផលលំបាកយ៉ាងខ្លាំងដោយសារ ធនធានជលផលបានត្រូវធ្លាក់ចុះយ៉ាង ខ្លាំង ដូច្នេះបានជាការនេសាទរបស់ ពួកគាត់រកចំណូលបានតិច។ ហើយ ម្យ៉ាងទៀតប្រជានេសាទនៅក្នុងតំបន់ ខ័ណ្ឌស្ទឹងហាវទាំងអស់ ត្រូវបង់ប្រាក់ អោយសមត្ថកិច្ចជំនាញជលផលមួយ ចំនួននៅស្រុកស្រែអំបិល ខេត្តកោះកុង ជារៀងរាល់ខែទៀត ដើម្បីធ្វើការ នេសាទដែលក្នុងការបង់ប្រាក់នោះក្នុង មួយខែមានចំនួនទឹកប្រាក់ចាប់ពី ៨០០បាត ទៅ១០០០បាត"។ ពួក គាត់បានបន្ថែម ទៀតថា "ដោយ មានការបង់ប្រាក់ អោយទៅគេរួច ហើយ នៅតែ មានការចាប់ទូក របស់ពួកគាត់ ទៀត មិនថាតែ សមត្ថកិច្ចជំនាញ នោះទេ ថែម ទាំងសហគមន៍ ទៀត ហើយអាជ្ញាធរដែលនៅជុំវិញ ខេត្តកោះកុងវិញ ដូចជានៅតំបន់ ថ្មរៀង កែវផុស ជ្រោយស្វាយ និង តំបន់ខ្សាច់ក្រហម ពួកគេសុទ្ធតែ ប្រកាសថា គេមានសិទ្ធិចេញមកចាប់ ទូកនេសាទរួមទាំងមេឃុំ មេភូមិ ក៏ អាចចេញមកចាប់ទូករបស់ពួកគាត់បាន ដែរ"។

អ្នកមីង **ស្រី ស៊ីនួន** អាយុ ៥០ឆ្នាំ ជាស្ត្រីមេម៉ាយដែលគាត់បានរស់នៅ ក្នុងភូមិលេខ១ សង្កាត់ទំនប់រលក ខ័ណ្ឌ ស្ទឹងហាវ បានចូលរួមបញ្ចេញយោបល់ ផងដែរថា "សព្វថ្ងៃនេះ ជីវភាពរបស់ គាត់ទទួលការលំបាកយ៉ាងខ្លាំងដោយ សារការរកចំណូលនៅក្នុងគ្រួសាររកបា នតិច ហើយគាត់ក៏បានអោយកូនស្រី ទៅស៊ីឈ្នួលបកសាច់ក្តាម សាច់បង្គា ដើម្បីយកប្រាក់ទាំងនេះ សំរាប់ផ្គត់ផ្គង់ ជីវភាពគ្រួសារ ហើយការស៊ីឈ្នួលបក សាច់ក្តាម បង្គា របស់កូនស្រីរបស់គាត់



ថតដោយ : ឈឹម សោភ័ក្រ

**អ្នកមីង ស្រី ស៊ីនួន**

ក្នុងមួយថ្ងៃបានប្រាក់ពី ៦០០០រៀល ទៅ ៧០០០រៀលតែប៉ុណ្ណោះ ចំណែក ឯកូនប្រុសរបស់គាត់ម្នាក់ទៀតបានទៅ ស៊ីឈ្នួលធ្វើការនេសាទជាមួយគេ (ធ្វើ

កូនដៃ) ក្នុងមួយថ្ងៃបានត្រឹមតែ ២000រៀល ទៅ៣000រៀល "។ គាត់បានមានប្រសាសន៏បន្ថែមទៀតថា " ចំណូលបានពីការបកសាច់ក្តាម បង្គា និងធ្វើការនេសាទជាមួយគេដោយកូនទាំងពីររបស់គាត់នេះ បើគិតទៅវាបានប្រាក់តិចណាស់សំរាប់ផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ ដូចជាការហូបចុកមិនបានគ្រប់គ្រាន់ មិនអាចផ្តល់លុយអោយកូនទៅរៀនបន្តបាន ដូច្នេះហើយបានជាគាត់ត្រូវបញ្ឈប់កូនរៀននៅថ្នាក់ទី៣ "។

នៅពេលដែលរដូវបកសាច់ក្តាមបង្គាមកដល់ កូនស្រីរបស់គាត់ទៅស៊ីឈ្នួលគេសំរាប់យកមកដោះស្រាយជីវភាព តែបើហួសរដូវបកសាច់ក្តាមបង្គាវិញ គាត់ព្រមទាំងកូន ត្រូវនាំគ្នាទៅជីករកខ្សៀវ និងខ្យងដើម្បីដោះស្រាយក្រពះមួយថ្ងៃ ។

លោក **កែវ វណ្ណឌី** អាយុ៣៧ ឆ្នាំ ជាប្រជានេសាទដែលរស់នៅ ភូមិលេខ១ សង្កាត់ទំនប់រលកបានមានប្រសាសន៏ថា "បច្ចុប្បន្ននេះប្រជានេសាទដែលរស់នៅក្នុងខ័ណ្ឌស្ទឹងហាវប្រមាណ ៨0% មានជីវភាពខ្វះខាត ហើយនៅពេលចេញទៅនេសាទមួយយប់អាចដោះស្រាយជីវភាពបានមួយថ្ងៃតែប៉ុណ្ណោះជួនកាលក្នុងការធ្វើនេសាទមួយជើងពេលខ្លះរកតែអោយថ្លៃប្រេងគេក៏មិនគ្រាន់ផង ហើយបើកាលណាគេចាប់ទៀតអស់ទាំងដើមអស់ទាំងផលនេសាទទៀតផង បើចង់បន្តការនេសាទទៀត គាត់ទាំងអស់គ្នាត្រូវតែទៅខ្ចីដើមទុនរបស់គេម្តងទៀតដើម្បីយកមកធ្វើការនេសាទ "។ គាត់បានបន្តទៀតថា "នៅឆ្នាំ១៩៨៦ការធ្វើនេសាទដោយរកត្រី បង្គា ក្តាម របស់ពួកគាត់មានការធូរធារច្រើនណាស់ដោយពេលនោះសំបូរធនធានធម្មជាតិ ហើយម្យ៉ាងទៀតទូកមានចំនួនប្រហែល៣0 ទៅ៤0ទូក។ លុះដល់ឆ្នាំ ១៩៩៥ ទៅ ១៩៩៦ ធនធានធម្មជាតិក៏នៅសំបូរដូចពីមុនដែរតែទូកនេសាទបានកើនឡើងពី ២00 ទៅ៣00ទូក " ។

លោក **គឹម ហាក់** អាយុ ៤៧ឆ្នាំ ជាមេភូមិនៅសង្កាត់ទំនប់រលក ខ័ណ្ឌស្ទឹងហាវ បានមានប្រសាសន៏ថា "ពីមុនគាត់បានប្រកបមុខរបរធ្វើការនេសាទដែរ តែនៅពេលនេះគាត់បានផ្លាស់ប្តូរមុខរបរពីការនេសាទមកធ្វើកសិកម្ម ដូចជា ចិញ្ចឹមទា ជ្រូកវិញ ដោយការនេសាទជួបផលលំបាកយ៉ាងខ្លាំង និងមានជនខិលខូចមួយចំនួនចាប់ជំរិតយកលុយ នៅពេលកំពុងធ្វើការនេសាទយ៉ាងអនាធិបតេយ្យ ធ្វើឱ្យមានការខាតបង់ច្រើន ដូច្នេះហើយ បានជាគាត់បែរទៅរករបរធ្វើកសិកម្មវិញ " ។

យើងសង្កេតឃើញថា ការរស់នៅក្នុងតំបន់ខ័ណ្ឌស្ទឹងហាវ ប្រជានេសាទមានការជួបផលលំបាកជាខ្លាំងដោយការនេសាទត្រី បង្គា បានតិចតួចដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ជាពិសេសមានការគាបសង្កត់យ៉ាងខ្លាំងពីអ្នកមានអំណាច។ ប្រជានេសាទនៅក្នុងខ័ណ្ឌស្ទឹងហាវទាំងអស់សំណូមពរដល់រាជរដ្ឋាភិបាលអោយជួយកែតម្រូវ

តទៅទំព័រ ៥


ថតដោយ : ឈឹម សោភ័ក្រ

**ការបកសាច់ក្តាមដើម្បីយកកំរៃឈ្នួលមកដោះស្រាយក្នុងជីវភាព**

# ការត្អូញត្អែររបស់ប្រជានេសាទបង្គានៅភូមិអន់ឆ្អើត

**ប្រជានេសាទនៅភូមិអន់ឆ្អើតបានត្អូញត្អែរថាការនេសាទបង្គាកាន់តែយូរទៅជីវភាពកាន់តែពិបាក ហើយនៅតែសង បំណុលគេមិនរួច .......... ។**

**អត្ថបទ: ចាន់ សុភក្រ្ត័**

ប្រមាណជា៤០គីឡូម៉ែត្រពីទីរួមស្រុកស្រែអំបិល មានភូមិមួយមានឈ្មោះថា"អន់ឆ្អើតស្ថិតក្នុងឃុំ ជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង ដែលមានប្រជាជន ១១៤គ្រួសារ ។ ប្រជាជនប្រមាណជា ៦៩ នៃប្រជាជនសរុបក្នុងភូមិបានយកមុខរបរនេសាទសំរាប់ការចិញ្ចឹមជីវិត ក្នុងនោះដែរបង្គាជាធនធានសមុទ្រសំខាន់ជាងគេបំផុតក្នុងចំណោមផលិតផលនេសាទទាំងអស់ដែលពួកគាត់នេសាទ។ ផ្ទុយទៅវិញ ប្រជាជនទាំងនោះបានត្អូញត្អែរថា ការនេសាទបង្គាកាន់តែយូរទៅជីវភាពកាន់តែពិបាកទៅៗ ហើយជំពាក់បំណុលគេកាន់តែច្រើនឡើងៗ ។ តាមលទ្ធផលនៃការសិក្សារបស់និស្សិតបរិស្ថានមួយក្រុមបាន អោយដឹងថាប្រជានេសាទប្រមាណជាជាង ៩០ ភាគរយក្នុងតំបន់នោះមានប្រាក់ចំណូលជាមធ្យមច្រើនជាង ១0000៛ ក្នុងមួយថ្ងៃនារដូវនេសាទបង្គា ។ នេះជាប្រាក់ចំនួលច្រើនបង្គួរដែរបើប្រៀបធៀបនឹងប្រជានេសាទទឹកសាប តើហេតុអ្វីបានជាប្រជានេសាទអន់ឆ្អើតត្អូញត្អែរថានេសាទយូរទៅកាន់តែជំពាក់បំណុលគេបែបនេះ?



ថតដោយ : ចាន់ សុភ័ក្រ្ត

**ទិដ្ឋភាពផែននេសាទតំបន់អន់ឆ្អើត**

តាមប្រសាសន៏របស់លោក **ខាត់ ជុំ** អាយុ៣៧ឆ្នាំ ដែលជាប្រជានេសាទមានស្រុកកំណើតនៅក្នុងភូមិអន់ឆ្អើតនេះតែម្តងនោះបានអោយដឹងថា ក្នុង-ការចេញទៅនេសាទបង្គាម្តងៗគាត់អាចរកប្រាក់ចំណូលជាមធ្យមប្រមាណជា២0000៛ដែរប៉ុន្តែគាត់ត្រូវចំណាយលើសាំងពី៤លីត្រ ទៅ៥លីត្រឯណោះក្នុងការចេញទៅនេសាសាទម្តងៗដោយសាំងមួយលីត្រតំលៃ២៥00រៀល ។ ម្យ៉ាងទៀតបង្គាដែលគាត់រកបានត្រូវតែលក់អោយដង្ហៅ( ជាអ្នកបណ្តាក់ឧបករណ៏នេសាទ) ក្នុងតំលៃថោកជាងតំលៃដែលឈ្មួញកណ្តាលដែលមកទិញបង្គាក្នុងភូមិរហូតដល់ទៅ១0.000រៀលទៅ១៥000រៀល ក្នុងបង្គា១គីឡូ-ក្រាម។ ដោយឡែកមងបង្គាដែលគាត់បណ្តាក់ពីដង្ហៅនោះមានរហូតដល់ទៅ៣២ដៃ ដោយក្នុង១ដៃតំលៃ៤0.000 រៀល ហើយអាចប្រើបានតែ២ ឬ៣ឆ្នាំប៉ុណ្ណោះ ហើយក្នុងមួយឆ្នាំគាត់ចេញទៅនេសាទបានតែ៦ខែប៉ុណ្ណោះ។ លើសពីនេះដោយអាស្រ័យលើចរន្តទឹកគឺក្នុង១ខែគឺនេសាទបានតែ១៥ថ្ងៃ។ គួរបញ្ជាក់

ដែរថា ឧបករណ៍នេសាទដែលប្រជាជនបានបណ្តាក់ពីដង្ហៅនោះ គឺមិនគិតការប្រាក់ទេ ប៉ុន្តែបង្គាដែលនេសាទបានត្រូវលក់អោយគេក្នុងតំលៃថោក ហើយថ្លៃជំពាក់ត្រូវតែសងវិញជាបណ្តើរៗតាមផលបង្គាដែលនេសាទបាន ។ ដូច្នេះហើយបានជាប្រជានេសាទភាគច្រើនសុទ្ធតែជំពាក់បំណុលគេ នៅតែដោះស្រាយពុំរួច ហើយបំណុលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ធ្វើអោយប្រជាជនទាំងនោះត្អូញត្អែរថា " ការនេសាទយូរៗទៅជំពាក់បំណុលឈ្នួញកាន់តែច្រើន និងដោះពុំរួច " ។

លោក **ហោ ហ៊ី** អាយុ៣៥ឆ្នាំ ដែលបានផ្លាស់មករស់នៅទីនេះអស់រយៈពេល១២ឆ្នាំមកហើយនោះបានអោយដឹងថាការប្រកបរបរនេសាទនេះគឺមិនត្រឹមតែចំណាយទៅលើសាំង និងឧបករណ៍នេសាទ ប៉ុណ្ណោះទេ គឺត្រូវចំណាយបន្ថែមទៀតទៅលើការជួសជុលទូកផងដែរដោយក្នុងមួយឆ្នាំៗគាត់ត្រូវចំនាយប្រាក់រហូតដល់ទៅ១៨0000រៀល ។ ជាងនេះទៅទៀតការនេសាទបង្គាមិនអាចនេសាទតែម្នាក់ឯងបានទេ គឺត្រូវជួលកូនដៃម្នាក់ដើម្បីទៅនេសាទជាមួយដោយគិតតំលៃអោយ១៥% បន្ទាប់ពីដកថ្លៃសាំងរួច ។ គាត់ក៏បានបន្ថែមទៀតថាបង្គាឆ្នាំនេះថោកជាងឆ្នាំមុនដោយបង្គាស ១គីឡូក្រាមមានតំលៃជាមធ្យម៩000រៀលទៅ១0000រៀល ហើយចំណែកឯបង្គាអៅខាក់តំលៃជាមធ្យម៤000រៀលទៅ៥000រៀលក្នុង១គីឡូក្រាមដែលតម្លៃនេះថោកជាងបណ្តាឆ្នាំកន្លងទៅច្រើន ។

ការនេសាទបង្គាពិតមែនតែរកប្រាក់ចំនូលបានច្រើនគួរសមក៏ពិតមែន ប៉ុន្តែការចំនាយលើការនេសាទ ក៏ច្រើនណាស់ដែរ គឺធ្វើឱ្យប្រាក់ចំនេញដែលទទួលបានតិចតួចបំផុត ។

តមកពីទំព័រ ១៨

## ជីវិតសត្វស្លាបទឹកក្នុង...

សត្វស្លាបទឹកដែលកំរនេះមកលក់ និងបរិភោគនៅតែកើតមាន ។ ជាចុងក្រោយនេះលោកបានសំណូមពរដល់អង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរមូលដ្ឋាន និងសហគមន៍សូមជួយថែរក្សាការអភិរក្សធនធាននេះ និងជួយសហការគ្នា ដើម្បីផលប្រយោជន៍ជាតិ ជាពិសេសទុកអោយកូនចៅជំនាន់ក្រោយបានស្គាល់នូវប្រភេទសត្វដែលកំរទាំងនេះផង ។

# អ្នកភូមិអន់ឆ្អើតមានសង្ឃឹម ក្រោយពីការបង្កើតសហគមន៍នេសាទ

**អត្ថបទ : សុវណ្ណ ច័ន្ទសុភក្រា**

ភូមិអន់ឆ្អើត ជាភូមិមួយស្ថិតក្នុងឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង ដែលមានប្រជាជនប្រមាណ ១១៤គ្រួសារ ដែលក្នុងនោះមានជាង ៥៩%ជាប្រជានេសាទ។ ទីនេះជាភូមិមួយក្នុងចំណោមភូមិទាំង៤ ក្នុងឃុំជីខក្រោម ដែលស្ថិតក្នុងសហគមន៍នេសាទតំបន់ឆ្នេរកោះខ្យង (ជាសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រដំបូងគេបំផុត)។ សហគមន៍នេះបានកកើតដោយមានការព្រមព្រៀងពីនាយកដ្ឋានជលផល និងប្រជាជនក្នុងតំបន់ដែលមានអង្គការ AFSC (អង្គការហ្វេកគ័រអាមេរិចកាំង) ជាអ្នកសំរបសំរួល ។ ការបង្កើតនេះមានគោលបំណងអោយប្រជាជនក្នុងតំបន់មានសិទ្ធិគ្រប់គ្រងនូវធនធានដែលខ្លួនមាន ដើម្បីអោយជីវភាពរបស់ពួកគាត់មានភាពធូរធារជាងមុន និងគ្រប់គ្រងធនធានដើម្បីអោយមានលក្ខណៈជានិរន្តរភាព ។ ដំណើរការសហគមន៍នេះបានទទួលនូវលទ្ធផលគួរជាទីគាប់ចិត្តដែលធ្វើអោយប្រជានេសាទមានការសប្បាយរីករាយយ៉ាងខ្លាំង។ យោងតាមសំដីរបស់លោកពូ **សាន់ យូ** អាយុ ៣៥ឆ្នាំ ជាប្រជានេសាទមានស្រុកកំណើតនៅក្នុងភូមិនេះបាននិយាយប្រាប់អោយដឹងថា "បន្ទាប់ពីបានបង្កើតសហគមន៍មកធនធានសមុទ្រនៅឆ្នាំថ្មីៗនេះមានការកើនឡើងជាងឆ្នាំមុនដែលគួរអោយកត់សំគាល់យ៉ាងខ្លាំងហើយធនធានសមុទ្រដែលមានការកើនឡើងដូចជាបង្គាអុកខាក និងត្រីកាម៉ុង ជាដើមដែលធ្វើឱ្យគាត់ចេញទៅនេសាទបានស្ទើរតែរាល់ថ្ងៃ។

លោកពូ **ចាន់ ប៊ុន** អាយុ ៤៧ ឆ្នាំបានមករស់នៅក្នុងភូមិនេះអស់រយៈពេល១១ឆ្នាំ បានមានប្រសាសន៍ថា "ការបង្កើតសហគមន៍នេះប្រជានេសាទក្នុងសហគមន៍បានចាត់តាំងវេនគ្នាចេញល្បាតក្នុងដែននេសាទសហគមន៍ដោយមានគ្នាប្រហែលជា២០ ទៅ៣០នាក់ទាំងយប់ទាំងថ្ងៃ ស្ទើរតែរៀងរាល់ថ្ងៃ។ នៅពេលដែលក្រុមល្បាតរបស់សហគមន៍បានជួបប្រទះនឹងពួកប្រព្រឹត្តបទល្មើសដែលចូលមកធ្វើការនេសាទក្នុងតំបន់ដែនសហគមន៍របស់គាត់ដោយប្រើឧករណ៍ខុសច្បាប់ដូចជា ទូកអួស ទូកឌុន ដែលតំរូវអោយពួកគាត់ត្រូវបង្ខំចិត្តចាប់យកឧបករណ៍ទាំងនោះមករក្សាទុក ឬឈានទៅដល់ការកំទេចចោល ក្នុងករណីដែលជនល្មើសមិនគោរពតាមការណែនាំពីសំណាក់ក្រុមល្បាត។ ក្នុងការបង្ក្រាបនេះពេលខ្លះ-ឈានទៅដល់ការទំនាស់ពាក្យសំដី និងការគុំគួនគ្នាជាដើម"។

កញ្ញា **ម៉ូវ សុំ** អាយុ ២១ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិខាងលើ



**តទៅទំព័រ ១៤**

# វេទិការប្រជានេសាទ

[illegible]

ខ្ញុំបាទឈ្មោះ [illegible] ស្រុកល្វាឯម ខេត្តកណ្ដាល [illegible]

[illegible] ខេត្តកណ្ដាល [illegible]

[illegible]

ទី១. [illegible]

ទី២. [illegible]

ទី៣- [illegible]

ទី៤. [illegible]

ទី៥. [illegible]

ទី៦- [illegible]

ទី៧- [illegible]

ទី៨ [illegible]

ទី ៩ [illegible] ... [illegible]

[illegible] ... [illegible]

[illegible] ... [illegible]

ទី 10- [illegible] ... [illegible]

[illegible] ... [illegible]

ធ្វើឲ្យ ប្រជាពលរដ្ឋ [illegible] ... [illegible]

[illegible] ធ្វើឲ្យ [illegible] ប្រជាពលរដ្ឋ មានសុខភាព [illegible]

ធ្វើនៅ ភូមិ [illegible] ថ្ងៃទី 05-08-2004

ហត្ថលេខា

[illegible]

# វេទិកាប្រជានេសាទ

## ឧបករណ៍នេសាទខុសច្បាប់

ដែលផ្ញើឲ្យមន្ត្រីជលផល វិនាស និង ម្ចាស់បង់

ន. កាលពីថ្ងៃទី16.17.09.2004 យើងខ្ញុំ បានទៅដល់ឃុំព្រៃយុថ្កា. ដែលមាន ចំណុះភូមិ 6. ស្រុកកោះអណ្ដែត ខេត្តតាកែវ បានសួរសំណួរ គណៈកម្មការសហគមន៍នេសាទ. មេភូមិ មេឃុំ ជំទប់ទី1. បានឃើញផ្ទាល់ នឹងក្រុមបាតុករ យើងខ្ញុំ សង្កេត. ព្រឹត្តការណ៍ នឹង ការប្រើ ឧបករណ៍ ខុសច្បាប់ ច្រើនប្រភេទ ដោយពីប្រទេស វៀតណាម ដែលប្រទេសកម្ពុជា យើង មិនដែលមាន. ហើយដែលមានសកម្មភាពពាសពេញ នៅលើទឹកដី. ឃុំព្រៃយុថ្កា. ស្រុកកោះអណ្ដែត ខេត្តតាកែវ

- ឧទាហរណ៍.

1. ឧបករណ៍. អាគុយឆក់. វៀតណាមហៅថា ដៀន.
2. ឧបករណ៍. អ៊ីវ៉ា. ត្រូមុង វៀតណាមហៅ ( ល្បៀ.
3. ឧបករណ៍. សំណាញ់ឆក់ ប្រើម៉ាស៊ីនភ្លើង ចាប់ដើម + អាគុយ.
4. ឧបករណ៍. លបឆក់ ទូឡយ បណ្ដោត ត្រី ប្រើអាគុយ.40
5. ឧបករណ៍. ទូក ដែលមានកន្ត្រៃឆក់ ប្រើអាគុយចាប់ត្រីអណ្ដែត
6. ឧបករណ៍. ស៊ីការ. យកម៉ាស៊ីនចាប់ទំពាំងដើម ប្រើអាគុយឆក់ (40->70)
7. ឧបករណ៍. ម៉ាស៊ីន បូម ប្រាជ ចាប់ត្រី ចរាចរលើ ដំណាំស្រូវ.

សរុប ឧបករណ៍. ទាំងអស់ខាងលើនេះ គឺវៀតណាម ប្រើប្រាស់ លើទឹកដីកម្ពុជា.

- សព្វថ្ងៃនេះ សកម្មភាព វៀតណាម ទាក់ទងនឹង អ៊ីវ៉ា ត្រូមុង. ហៅ. ល្បៀ. ហាប់ ម្ដង ឧកឡាស ព្រំដែន ឃុំព្រៃយុថ្កា ស្រុកកោះអណ្ដែត (តាកែវ) តាមបន្ទាត់ព្រំដែនកម្ពុជា. វៀតណាម ការប្រើ ទាន់ថ្មី យើងល្អក ល្អស់ ពាសពេញ. ខាងជិតនេះ លើទឹកដី ឃុំព្រៃយុថ្កា ស្រុកកោះអណ្ដែត.

*. សំនួរ. តើសកម្មភាពខាងលើនេះ ដាក់ទោសអ្នកណា ?

## *- ការទទួលប្រាក់ពីបទល្មើស . ទៀតហើយ

- កាលពីថ្ងៃទី16.17.09.04. ប្រជាពលរដ្ឋ ក្នុងឃុំបញ្ញា ឈ្មោះ
បានឲ្យដឹងថា. មន្ត្រីជំនាញ + សមត្ថកិច្ច. ផលផល ទៀនរស៊ីបជាប់ត្រី

. ជំរុំផលផល. ចំណែកចំណែត យកទទួលប្រាក់ពីបទល្មើស ទៀតហើយ.
កាប់ឈើទៀត ពីននល្មើស. ម្នាក់ៗ ។

សំនួរ. តើ មន្ត្រីផលផល + សមត្ថកិច្ច នៅដំបន់នេះ តើធនធាន ផលផល.
. វិនាស បាត់បង់ អស់ឬទេ ?

យើងខ្ញុំ សាកសួរនេះ ក្នុងនាម ក្រុមនេសាទ + អាជ្ញាធរ កិច្ចការ ជំពោះ អ្នក:
គ្រប់គ្រង + ការពារ ធនធាន ទេ មិនចឹមនៅ សាលាក្សា រំលោភ ទៀតហើយ ។

ធ្វើនៅថ្ងៃ19.09.2004.
ហត្ថលេខា.

[signature] ម៉ុត ណាំង

តំណាង ប្រជានេសាទ (ភ្នំពេញ)

# អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល
# និង
# គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា

FACT-AS-VSG-CDP-LICADHO-ADHOC-KKKHRA-LAC-Vigilance-KKKHRDA

ទូរស័ព្ទទំនាក់ទំនង :០២៣៩៩៤០៨៥ ០៩៣៩៩៣១៧០ ០៩៣៩៩២៨២៨ ០៩៣៩៩២៨២៩ ០៩៣៩៩៣៣០៧

លេខៈ០៩..សភជផ

**គោរពជូន**

**ឯកឧត្តមអភិបាលខេត្ត បាត់ដំបង**

**សូមបានជ្រាប ៗ**

**កម្មវត្ថុ:** សំណើសុំឯកឧត្តមអភិបាលខេត្ត ជួយធ្វើអន្តរាគមន៍ដល់ប្រជាពលរដ្ឋរស់នៅចំណុចពាក់កន្ទេល ឃុំកោះជីវាំង ស្រុកឯកភ្នំ ។

**យោងៈ** របាយការណ៍ ស្តីពី បញ្ហាប្រឈមមុខរបស់ប្រជាពលរដ្ឋ ត្រៀមជំលៀសចេញពី ភូមិពាក់កន្ទេល ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង

តតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំទាំងអស់គ្នាតំណាងអោយអង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល និងគណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា ខេត្ត បាត់ដំបង បាន ទទួលរបាយការណ៍ពីប្រជាពលរដ្ឋរស់នៅចំណុចពាក់កន្ទេល ឃុំកោះជីវាំង ស្រុកឯកភ្នំ កាល ពីថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០០៤ ដែលយើងខ្ញុំសូមធ្វើការសង្ខេបជូនដូចខាងក្រោមៈ

នៅព្រឹកថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៤ គណៈប្រតិភូខេត្ត ដែលដឹកនាំដោយលោក **អៀ វ៉ាន់នី** ប្រធាន មន្ទីរទំនាក់ ទំនង រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត រួមដំណើរដោយលោក អនុប្រធានមន្ទីរ កសិកម្មខេត្ត លោកអនុ ប្រធានក្ខាមរួមការិយាល័យជលផលខេត្ត លោក អភិបាលស្រុកឯកភ្នំ និងកង កំលាំង ប្រដាប់អាវុធ បាន ចុះទៅធ្វើការផ្សព្វផ្សាយដល់ ប្រជា ពលរដ្ឋ ពាក់កន្ទេល ឃុំកោះជីវាំង ។ ក្នុងការ ផ្សព្វផ្សាយនោះ គណៈប្រតិភូបាន អនុញ្ញាតិអោយតំណាងប្រជាពលរដ្ឋចំនួន ០៩នាក់ដើម្បី ចូលរួមស្តាប់ពី លទ្ធផលដោះស្រាយទំនាស់នៅចំណុចពាក់ កន្ទេលរបស់លោក **អៀ វ៉ាន់នី** ដោយសង្កត់ធ្ងន់ថា ចំណុច ពាក់ កន្ទេលមិនត្រូវបានអនុញ្ញាតិអោយបង្កើតជាភូមិ ស្របច្បាប់ទេដោយៈ

១-ចំណុចពាក់កន្ទេលឋិតនៅក្នុងឡូតិ៍នេសាទលេខ១ និងលេខ២

២-ប្រជាពលរដ្ឋរស់នៅដោយចល័តតាមរដូវកាលរហូត

៣-ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ពាក់កន្ទេល បានបង្កអោយប៉ះពាល់ដល់ដែនជីវសាស្រ្តចំរុះសំរាប់ អភិរក្ស និងការ ពារធនធានធម្មជាតិ ជាពិសេសពពួកសត្វស្លាបទឹក ។ ក្រៅពីនេះប្រជានេសាទកាន់តែកើន ច្រើនឡើងធ្វើ អោយរំខានដល់ឡូតិ៍ ពេលខ្លះមានជនខិលខូចមួយចំនួនបានលបលួចចូលទៅរកនេសាទត្រី នៅក្នុងឡូតិ៍ ដែលជា ហេតុបង្កការលំបាកដល់ ម្ចាស់ឡូតិ៍ ។

នេះជារបាយការណ៍មិនទាន់គ្រប់ជ្រុងជ្រោយដោយប្រជាពលរដ្ឋបានអះអាងថា អ្នកដែលធ្វើអោយប៉ះពាល់ដល់ សត្វស្លាបទឹក និងជីវៈចំរុះនៅទីនោះគឺម្ចាស់ឡូតិ៍នេសាទ និងអ្នកជួលឡូតិ៍បន្ត ព្រោះអ្នកទាំង អស់នេះ បានប្រើប្រាស់ឧបករណ៍ ឆក់ បូមពង្រីង និងកាប់ព្រៃលិចទឹកដើម្បីរត់ព្រួលក្នុងនាទីឡូតិ៍ ។ ការ រត់ព្រួលម្ចាស់ឡូតិ៍ នេសាទបានធ្វើទាំងរដូវបើក និងរដូវបិទនេសាទ ។

នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០០៤ លោកប្រធានមន្ទីរទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការ កិច្ចខេត្តបាត់ ដំបង លោកអភិបាលស្រុកឯកភ្នំ លោកមេឃុំកោះជីវាំង នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំកោះ ជីវាំងរួមទាំងកងកំលាំង ប្រដាប់អាវុធ ផ្សេងទៀត បានមកធ្វើសកម្មភាពអូសទាញយកសាលារៀន ព្រម ទាំងចាប់ខ្លួនលោក **មិន ផល** ជាគ្រូ បង្រៀន និងលោក **មិន សុខ** ជាមេភូមិបណ្តោះអាសន្នឃុំខ្លួននៅ ផ្ទះផែម្ចាស់ឡូតិ៍លេខ២ អស់រយៈ ពេល២ម៉ោង និង ៣០នាទី ។ កងកំលាំងទាំងនេះមានកាំភ្លើងអាកា ចំនួនជាង១០ដើម ។ ដោយមានការតវ៉ា ពីប្រជាជននៅទីនោះ សាលារៀនមិនត្រូវបានគេទាញចេញពីភូមិ នោះទេ ក្នុងអំឡុងពេលនោះ កងកំលាំងប្រដាប់ អាវុធ បានបើកសោរកាំភ្លើង ហើយ អាមេ ធ្វើអោយ សិស្សចំនួន ២នាក់ ផ្អើលរត់ដួលធ្លាក់បែកក្បាល ។ ប្រជាជន បាននាំគ្នាយកម៉ាស៊ីនថត ដើម្បីថត សកម្មភាព កងកំលាំងទាំងនោះទុកជាភស្តុតាងនៅពេលដែលកងកំលាំង ប្រដាប់អាវុធកំពុងធ្វើសកម្មភាពគំរាមកំហែង ប្រជាជនស្រាប់តែកងកំលាំងទាំងនោះគំរាមដាក់ខ្នោះ ។ ដោយមាន ការតវ៉ាខ្លាំងពីប្រជាជន ទើបកងកំលាំង ប្រដាប់ ដោយអាវុធ មិនបានដាក់ខ្នោះទេ ។ ម្យ៉ាងទៀតនៅពេលដែល ប្រជាជនធ្វើការតវ៉ា កងកំលាំង ប្រដាប់អាវុធទាំងនោះ គំរាមកំហែងរកបាញ់សំលាប់ ។

នៅព្រឹកថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៤ យោធាតំបន់ប្រតិបត្តិការខេត្ត រួមនឹងប៉ូលីសរដ្ឋបាលឃុំកោះជីវាំង ចំនួន៤នាក់ប្រដាប់ដោយកាំភ្លើង អាកាបានអូសផែម្ចាស់ឡូតិ៍នេសាទលេខ២ទៅចតនៅពីមុខ សាលារៀនពាក់ កន្ទេល ដែលធ្វើអោយមានការលំបាកដល់ ប្រជាពលរដ្ឋ និងសិស្សានុសិស្សចូលទូកទៅ សាលារៀន ។ នៅពេល បច្ចុប្បន្ន ក្រុមនេះបានបោះទីតាំងក្នុងតំបន់ ពាក់កន្ទេល ដើម្បី ដើរប្រមូលប្រាក់ពី ប្រជានេសាទតូចតាចដែលដាក់លបនៅតំបន់នោះ ដោយយកលេសថា អ្នកនេសាទ ទាំងនេះរកត្រី នៅរដូវបិទនេសាទ ។

អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល(FACT) និង គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃសមាគមការពារសិទ្ធិមនុស្ស ខេត្តបាត់ដំបង សូមបញ្ជាក់ឱ្យឃើញថា ព្រឹត្តិការណ៍ដែលបានកើតឡើងនៅថ្ងៃទី ០៤ ខែសីហា និងថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៤ នោះជាអំពើប៉ុនប៉ងជំលៀសប្រជាជនចេញដោយគ្មានតម្លាភាព

និងប្រើអំពើហិង្សាចាប់គំរាមកំហែងដោយអាវុធ នាំអោយមានការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរមួយ ហើយនិងអាចកើតមានជាបន្តបន្ទាប់ប្រសិនបើគ្មានការទប់ស្កាត់ ។

**អាស្រ័យដូចជំរាបជូនខាងលើ** សូមឯកឧត្តមមេត្តាជួយធ្វើអន្តរាគមន៍ ដើម្បីទប់ស្កាត់ភាពមិនប្រក្រតី **ដែលបានកើតមាននៅភូមិ**ពាក់កន្ទេល ឃុំកោះជីវាំង ស្រុកឯកភ្នំ ដោយសេចក្តីអនុគ្រោះ ។

-ជូនភ្ជាប់មកជាមួយ របាយការណ៍លំអិតចំនួន០១ច្បាប់

**ចំលងជូន**

-គណៈកម្មាធិការប្រព្រឹត្តិកម្មភ្នំពេញ

-ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំខេត្តបាត់ដំបង

"ជ្រាបជាពតិមាន"

-ឯកសារកាលប្បវត្តិ

ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៤

FACT

LICADHO

Vigilance

KKKHRDA

VSG

ADHOC

AS

KKKHRA

CDP

LAC

ព្រះរាជាណាចក្រ កម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

48
13 9 2004

លិខិត សំណើ

យើងខ្ញុំជាសមាជិក សហគមន៍ នេសាទ ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត

សូមគោរពជូនមក

ឯកឧត្តមអភិបាលខេត្ត កំពត
តាមរយៈលោកមេឃុំព្រែកត្នោត
លោកអភិបាលស្រុកកំពត
លោកប្រធានការិយាល័យជលផលខេត្ត កំពត

កម្មវត្ថុ ៖ ស្តីពីបទល្មើសនេសាទ ឧបករណ៍ និងឧបករណ៍ខុសច្បាប់ក្នុងតំបន់ទឹករាក់

តាមកម្មវត្ថុ ខាងលើនេះ ខ្ញុំសូមជំរាប ឯកឧត្តមអភិបាល ខេត្ត មេត្តាជ្រាបថា សព្វថ្ងៃនៅតំបន់ឆ្នេរសមុទ្រ ឃុំព្រែកត្នោតមានបទល្មើសនេសាទឧបករណ៍ និងឧបករណ៍ខុសច្បាប់ ក្នុងតំបន់ទឹករាក់យ៉ាងរញ៉េរញ៉ៃ ដែលជាហេតុធ្វើអោយប៉ះពាល់ដល់ប្រជានេសាទតូចតាចជាសាក្រីក្រ ជួបការលំបាកក្នុងជីវភាពប្រចាំថ្ងៃយ៉ាងខ្លាំង ហើយឃុំព្រែកត្នោត សព្វថ្ងៃបានបង្កើតសហគមន៍នេសាទ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០០២ មកម្លេះ ប៉ុន្តែមកដល់ពេលនេះពុំមានឃើញមានដំណើរការទេ ហើយគឺបានតែត្រឹមបង្កើតមិនមានសិទ្ធិ ក្នុងការចុះល្បាតពិនិត្យ បទល្មើសទេ ជាហេតុធ្វើអោយជនប្រព្រឹត្តបទល្មើសនៅតែធ្វើ សកម្មភាពមិនមានកោតខ្លាចទេ ហើយសកម្មភាពទាំងនេះធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពអ្នកនេសាទតូចតាចក្រីក្រកាន់តែខ្លាំងឡើង

អាស្រ័យហេតុដូចបានជំរាបខាងលើនេះ យើងខ្ញុំទាំងអស់គ្នា សូមឯកឧត្តម មេត្តាពិនិត្យ និងជួយ ដោះស្រាយជូនយើងខ្ញុំតាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ

ព្រែកត្នោត ថ្ងៃទី២ ខែកក្កដា 04
តំណាងសមាជិកនេសាទ

សី ឡោះ     ហឹម សារ

ឃើញ ត្រឹមត្រូវ ...
ថ្ងៃទី០៩.៤.០៤

# អត្ថបទស្រាវជ្រាវ: អត្ថបទសង្ខេបពីសារព័ត៌មាននានា ស្តីអំពីបញ្ហាវិស័យជលផល ខែ កក្កដា ~ សីហា ឆ្នាំ ២០០៤

**ដកស្រង់ដោយ: ក.ចាប សុធារី**

- **កណ្តាល:** លោក **ឃី ធី** នាយសង្កាត់នេសាទស្រុកស្អាង និងស្រុកតាខ្មៅ បានរួមសហការជាមួយកងប្រដាប់អាវុធ និងក្រុមប្រឹក្សាឃុំ ចុះបង្ក្រាបឧបករណ៍នេសាទខុសច្បាប់ ចាប់តាំងពីថ្ងៃទី ០១ កក្កដា រហូតដល់ថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៤។ លោកបានមានប្រសាសន៍ថា លទ្ធផលនៃការបង្ក្រាបរហូតដល់បច្ចុប្បន្ននេះគឺបង្ក្រាបបានពី ៧០%ទៅ ៨០% ហើយដែលក្នុងនោះបានកំទេចរបាំងផ្ចិតព្រែក៣៨របាំង ព្រួល៩៤១ម៉ែត្រ លប និងទ្រូចំនួន៦០បង្គោល ៤៤៦ដើម លូស្បៃមុង៤៩៥មាត់លូ ព្រួលស្បៃមុង២៩.៥៩២ម៉ែត្រ ព្រួលស្បៃ ១.០៥០ម៉ែត្រ និងអួនស្បៃមុង ៣វង់ ប្រវែង៤៥០ម៉ែត្រ។ លោកបន្តថាការចុះបង្ក្រាបនេះមានការលំបាកហាក់ដូចជាវែកចេកព្រោះការបង្ក្រាបបានស្ងាត់តែមួយរយៈក្រោយមកបទល្មើសនេះនៅតែកើតមាន ប៉ុន្តែទោះជាយ៉ាងណាក៏លោកនៅតែបន្តបង្ក្រាបជានិច្ច។

( *កោះសន្តិភាព ឆ្នាំទី ៣៧ លេខ ៥១ ០២ ចេញផ្សាយថ្ងៃអង្គារ៍ ទី ១៥ ខែ សីហា ឆ្នាំ ២០០៤*)

- **បាត់ដំបង:** ប្រជានេសាទម្នាក់ដែលសូមមិនបញ្ចេញឈ្មោះបានអោយដឹងថា សព្វថ្ងៃនេះនៅឡូត៍នេសាទលេខ១ លេខ២ និងឡូត៍ផ្សេងៗទៀតកំពុងធ្វើសកម្មភាពកាប់បំផ្លាញព្រៃលិចទឹកសម្រាប់បោះបង្គោលរត់ព្រួល ណរ៉ាវក្នុងរដូវបិទនេសាទ យ៉ាងគគ្រឹកគគ្រេងសុសសាច់ព្រៃ ចាប់តាំងពីមាត់បឹងទន្លេសាបចូលមកដល់ក្នុងព្រៃរនាមដែលមួយខ្សែៗមានបណ្តោយរហូតដល់ប្រមាណ ៣០គីឡូម៉ែត្រ។ ចំពោះការកាប់បំផ្លាញព្រៃលិចទឹកក្នុងរដូវត្រីពងគឺនាំអោយរេចរិលព្រៃ ខ្វះចំណីត្រី ខ្វះជម្រកសំរាប់ត្រីពង ។ចំណែកឯរ៉ាវិញជារនាំងមិនអោយត្រីរកព្រៃសម្រាប់កាច់សម្បុកពងបាន ជាហេតុនាំអោយមេត្រីរាកពងចោលងាប់ពងត្រីអស់ ហើយមេត្រីទាំងនោះក៏ត្រូវចូលក្នុងលបដាច់ពូជតែម្តង។

( *រស្មីកម្ពុជា ឆ្នាំទី ១២ លេខ៣៤៦១ ចេញផ្សាយថ្ងៃអាទិត្យ-ច័ន្ទ ទី ២៩-៣០ ខែ សីហា ឆ្នាំ ២០០៤*)

- **កំពង់ស្ពឺ:** កូនត្រីឆ្លិនចំនួន២ម៉ឺនក្បាលដែលបានមកពីការជួយឧបត្ថម្ភរបស់នាយកដ្ឋានជលផលនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទត្រូវបានមន្ទីរកសិកម្មខេត្តកំពង់ស្ពឺរួមជាមួយអាជ្ញាធរខេត្តយកទៅលែងនៅក្នុងបឹងធម្មជាតិមួយក្នុងអាងទឹកទំនប់ចាន់ថ្នាល ឃុំក្រាំងចេក ស្រុកឧត្តុង្គ ខេត្ត កំពង់ស្ពឺ នៅព្រឹកថ្ងៃទី ២១ ខែ-សីហា ឆ្នាំ២០០៤ នេះ។ លោក **អ៊ុំ ម៉ុន** អភិបាលខេត្តកំពង់ស្ពឺ បានថ្លែងអោយដឹងក្នុងថ្ងៃលែងកូនត្រីនោះថា ការលែងកូនត្រីក្នុងបឹងធម្មជាតិ គឺជាសកម្មភាពមួយក្នុងការបំផុសចលនាថែរក្សាការពារ និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ស្របតាមអនុក្រឹត្យរបស់រដ្ឋាភិបាលស្តីពីការបង្កើតទិវាមច្ឆជាតិ ក៏ដូចជាស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ននៃការថយចុះ របស់មច្ឆជាតិ។

( *រស្មីកម្ពុជា ឆ្នាំទី ១២ លេខ៣៤៥៧ ចេញផ្សាយថ្ងៃពុធ ទី ២៥ ខែ សីហា ឆ្នាំ ២០០៤*)

- **សៀមរាប:** ប្រភពពត៌មានគួរអោយទុកចិត្តមួយបានអោយដឹងថា បទល្មើសនេសាទបានកើតឡើងយ៉ាងពេញបន្ទុកនៅខេត្តសៀមរាបនៅក្នុងរដូវបិទនេសាទ ហើយការកើតមានករណីនេសាទល្មើសច្បាប់នេះ គឺជា

បច្ច័យមួយមិនល្អទេសំរាប់ការថែរក្សា ក៏ដូចជាការអភិរក្សភោគផលមច្ឆាជាតិទៀតផង ដោយសារតែរដូវកាលនេះជារដូវត្រីពង។ ទាក់ទងនឹងការធ្វើនេសាទក្នុងរដូវហាមឃាត់នេះ រាជរដ្ឋាភិបាលបានចេញសេចក្តីប្រកាសលេខ ០២ ប្រ.ក ស្តីពីវិធានការគ្រប់គ្រង់ និងលុបបំបាត់ភាពអាណាធិបតេយ្យនៅក្នុងវិស័យជលផលត្រង់ចំនុចទី៤ បានចែងថាត្រូវបញ្ឈប់ការនេសាទដោយខុសច្បាប់នៅក្នុងរដូវបិទនេសាទ ។ *(កោះសន្តិភាព ថ្ងៃពុធ ទី១៤-១៥ សីហា ឆ្នាំ ២០០៤)*

- **ភ្នំពេញៈ** ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្តីជូនដំណឹងជាសាធារណៈមួយប្រយោជន៍ដល់ប្រជាពលរដ្ឋទូទាំងប្រទេសអោយប្រុងប្រយ័ត្នក្នុងការបរិភោគប្រភេទកំពតមានជាតិពុលដែលបណ្តាលអោយមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិត។ លោក **ណៅ ធុក** ប្រធាន-នាយកដ្ឋានជលផលបានអោយដឹងថាៈ ករណីពុលមាន២យ៉ាងគឺ ខ្លួនត្រីមាន-ជាតិពុល និងបញ្ចេញសារធាតុពុលនៅរដូវពងកូនចាប់ពីខែកក្កដា ដល់កញ្ញា។ ជាទូទៅប្រភេទកំពតនេះរស់នៅតំបន់មានក្រួស ថ្មនាតំបន់ដាច់ស្រយាលតាមអូរ ព្រែក តែមិនសូវឃើញនៅបឹងទន្លេសាបទេ។ កំពតប្រភេទ Monotreta fangi មានជាតិពលកំរិតមធ្យម។ ប្រជាពលរដ្ឋត្រូវចំណាំអោយច្បាស់វាមានស្នាមអុជពណ៌ខ្មៅធំមួយដោយមានព័ទ្ធជុំវិញនូវរង្វង់ពណ៌លឿង-សនៅចំហៀងខ្លួនជិតគល់កន្ទុយ។ ប្រភេទ Monotreta Leiurus មានស្នាមអុជពណ៌ខ្មៅធំៗជាច្រើននៅលើផ្ទៃដងខ្លួនដោយមានរង្វង់ពណ៌លឿង-ស ព័ទ្ធជុំវិញស្នាមអុជខ្មៅទាំងនោះផង។ *(រស្មីកម្ពុជា ឆ្នាំទី ១២ លេខ៣៤៥៥ ចេញផ្សាយថ្ងៃអាទិត្យ-ច័ន្ទ ទី ២២-២៣ ខែ សីហា ឆ្នាំ ២០០៤)*

- លោក **សេង ទឹម** នាយសង្កាត់ នេ-សាទប្រចាំស្រុកពញាឮ បាននិយាយនាថ្ងៃទី ២៣ ខែកក្កដានេះថាៈ បទល្មើសនេសាទបានកើតមានតិចតួចណាស់ក្នុងរដូវបិទនេសាទនេះ ដោយសារថ្នាក់លើបានដាក់បញ្ជាឱ្យឃ្លាំមើលជាប្រចាំ និងចុះបង្រ្កាបទាន់ពេលវេលា ដើម្បីការពារត្រីគ្រប់ប្រភេទក្នុងរដូវពងកូន។ បច្ចុប្បន្ននេះគ្មានសកម្មភាពនេសាទល្មើសច្បាប់ទេ ព្រោះមានក្រុមអធិការកិច្ចជលផលចតុមុខក្រុមអធិការកិច្ចជលផលនាយកដ្ឋាន និងខេត្តបានចុះចល័តជាញឹកញាប់សហការជាមួយមន្ត្រីជលផលប្រចាំសង្កាត់នេសាទ។ *(រស្មីកម្ពុជា ឆ្នាំទី ១២ លេខ៣៤៣៦ ចេញផ្សាយថ្ងៃសៅរ៍ ទី ៣១ ខែ កក្កដា ឆ្នាំ ២០០៤)*

-**ក្រុងព្រះសីហនុៈ** លោក **នៅ រតនា** ប្រធានមន្ទីរកសិកម្មក្រុងព្រះសីហនុបានថ្លែងអោយដឹងថា ពិធីលែងត្រីក្នុងទិវាមច្ឆាជាតិនេះគឺជាលើកទីពីរ ហើយដែលមន្ទីរកសិកម្មក្រុងបានយកចិត្តទុកដាក់លើការបណ្តុះបណ្តាលពូជត្រីតាមលក្ខណៈធម្មជាតិឡើងវិញ សំដៅលើកស្ទួចដល់ធនធាន ពូជត្រីក្នុងស្រុកអោយកាន់តែច្រើនក្នុងគោលបំណងបំរើអោយតំរូវការនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅកាន់ជនបទអោយកាន់តែប្រសើរឡើងថែមទៀត។ លោកបានអោយដឹងផងដែរ លើកទីមួយយើងបានធ្វើការប្រលែងកូនត្រីពូជចំនួន២ម៉ឺនក្បាលចូលទៅក្នុងអាងស្តុកទឹកក្នុងសង្កាត់អូរឧកញ៉ាហេង ក្នុងខណ្ឌព្រៃនប់ដែរ និងលើកទីពីរនេះចំនួន៣ម៉ឺនក្បាលថែមទៀត ។ *(កោះសន្តិភាព ឆ្នាំទី ៣៧ លេខ៥១៦៣ ចេញផ្សាយថ្ងៃសៅរ៍-អាទិត្យ ទី៣-៤ ខែកក្កដា ឆ្នាំ ២០០៤)*

## នាទីកំណាព្យ

# ខ្ញុំអ្នកឆក់ត្រី

### បទកាកគតិ

- ខ្ញុំអ្នកឆក់ត្រី បានតិចក្តីច្រើនក្តី លក់យកលុយចាយ
ថ្ងៃណាសំណាង បានច្រើនម៉ឺនបួយ រីករាយសប្បាយ
គ្មានខ្វាយខ្វល់ទេ ។

- ខូបប្រាំវស្សា ខ្ញុំរើសយកការ ងារក្នុងទន្លេ
ជូនចូលទោបឹង ដងស្ទឹងជើងទេរ ពុំសូវទំនេរ
រិះរកឆក់ត្រី ។

- ពេលយប់ព្រលប់ ក៏ខ្ញុំមិនឈប់ នៅស្ងៀមធ្វើហី
យប់ជ្រៅគេដេក ខ្ញុំដើរចុះដី ឆ្លងវាលចូលព្រៃ
ឆក់ត្រីក្នុងបឹង ។

- ពេលត្រីសំបូរ លុយបានហែហូរ ព្រោះការខំប្រឹង
រឿងស្រែចំការ ខ្ញុំមិនបាច់ដឹង រកស៊ីខាងហ្នឹង
មិនបានទាន់មាត់ ។

- ឥឡូវត្រីខ្សត់ ពូជធាររលត់ គ្មានត្រីធំធាត់
នេសាទខុសច្បាប់ រីករាលពេញរដ្ឋ ខ្មែរឯងវាយវាត់
ភ្លាត់បំផ្លាញជាតិ ។

- ជីវភាពពួកខ្ញុំ ធ្លាក់យ៉ាប់យ៉ាងធំ ខុសប្លែកអស់ញាតិ
ខ្ញុំធ្លាប់ពឹងត្រី ឥឡូវខកស្មៀត រឿងឆក់កញ្ឆៀត
ចោលម្សៀតគ្មានល្អៃ ។

- ងាកទៅខាងណា ទៅធ្វើចំការ ឬទៅធ្វើស្រែ
ដីលក់ដូរអស់ គេរកោះពុកម៉ែ សម្បត្តិក្បែរៗ
អត់ថៃលក់ចាយ ។

- ខ្ញុំអាងឆក់ត្រី ឥឡូវល្វិតល្វៃ ខ្វះខាតរឿងបាយ
រកសីមួយតែ បង្កអន្តរាយ ខូតខាតវែងឆ្ងាយ
ក្លាយល្មើសច្បាប់ទៀត ។

- អាជ្ញាធរដាស់ ប្រកូកប្រកាស ប្រាប់អស់ញោមញាតិ
ជួយកែជួយពត់ គំនិតមារយាទ ការពារធម្មជាតិ
ធនធានផលត្រី ។

- ខ្ញុំអ្នកនេសាទ កែចិត្តអោយស្អាត គោរពវិន័យ
លែងឆក់លែងដាក់ ព័ទ្ធស្នាក់អួនសៃ្ប លែងប្រព្រឹត្តអ្វី
ហៅថាល្មើសច្បាប់ ។

**រៀបរៀងដោយៈ ទេព ចូង**
**សមាជិក គ ជ ម ឃុំព្រែករៃ ស្រុកល្វាឯម**

# សមាជិកបណ្តាញការងារ សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល

| ខេត្ត/ក្រុង | ឈ្មោះអង្គការ |
|---|---|
| ភ្នំពេញ | ១.វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា<br>*(NGO forum on Cambodia)*<br>២.អុកស្វាមអាមេរិក<br>*(Oxfam US)*<br>៣.សមាគមថែររក្សាបរិស្ថាន និងវប្បធម៌<br>*Culture and Environment Preservation Association (CEPA)*<br>៤.អង្គការអន្តរជាតិស្ម័គ្រចិត្តជប៉ុន<br>*Japan International Volunteer Center (JVC)*<br>៥.មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា<br>*Centre d'Etude et de Dévelopment Agricole Cambodgien (CEDAC)* |
| កណ្តាល | ១.សមាគមកសិករខ្មែរ<br>*Khmer Farmer Association (KFA)* |
| ក្រចេះ | ១.សហគមន៍ជំនួយក្រៅប្រទេស<br>*Community Aid Abroad (CAA)* |
| ព្រៃវែង | ១.អង្គការសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍នៅកម្ពុជា<br>*Partnership for Development in Cambodia (PADEK)* |
| សៀមរាប | ១.អង្គការចូលរួមអភិរក្សតំបន់អង្គរ (APDO)<br>២.អង្គការខ្មែរអភិវឌ្ឍន៍ខ្មែរ (KAKO) |
| កំពង់ចាម | ១.សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា<br>*Cambodian Human Rights and Development Association (ADHOC)*<br>២.អ្នកអភិវឌ្ឍន៍សហគមន៍<br>*Nak Akphivath Sahakum (NAS)*<br>៣.សមាគមភ្នំស្រីដើម្បីអភិវឌ្ឍន៍<br>*Phnom Srey Association for Development (PSAD)* |
| តាកែវ | ១.អង្គការចំរើនជាតិខ្មែរ<br>*Chamroen Chiet Khmer (CCK)* |
| ស្ទឹងត្រែង | ១.សមាគមថែររក្សាបរិស្ថាន និងវប្បធម៌<br>*Culture and Environment Preservation Associat on (CEPA)* |
| កោះកុង | ១.គណៈកម្មការបំរើអេក្វាត័រអាមេរិកកាំង<br>*American Friends Service Committee (AFSC)* |

| | |
|---|---|
| **កំពង់ឆ្នាំង** | ១.អង្គការកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍<br>*Community Poverty Reduction (CPR)*<br>**២.អង្គការបង្កើនសមត្ថភាពសហគមន៍ ដើម្បីអភិវឌ្ឍន៍**<br>*Community Capacity Building for Development (CCD)*<br>៣.សមាគមភ្នំនាងកន្រ្ទី<br>*Phnom Neang Kanrei Association (PNKA)*<br>៤.អង្គការទស្សនៈពិភពលោកកម្ពុជា<br>*World Vision-Cambodia (WVC)*<br>៥.សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម<br>*Khmer Kampuchea Krom Human Rights Association (KKKHRA)* |
| **បាត់ដំបង** | ១.អង្គការអភិវឌ្ឍន៍ស្ត្រី<br>*Akphiwat Strey (AS)*<br>២.អង្គការក្រុមអភិវឌ្ឍន៍ភូមិ<br>*Krom Akphiwat Phum (KAWP)*<br>៣.អង្គការលូស៊ីណា<br>*Leucaena Communication Japonesia (LCJ)*<br>៤.អង្គការសហគមន៍ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ<br>*Khmer National Community Economic Development (KNCED)*<br>៥.អង្គការក្រុមទ្រទ្រង់ភូមិ<br>*Village Support Group (VSG)*<br>៦.អង្គការបំរើគ្រួសារដើម្បីអភិវឌ្ឍន៍កម្ពុជា<br>*Cambodia Family Development Services (CFDS)* |
| **កំពង់ធំ** | ១.អង្គការគ្រីស្តសាសនាបំរើពិភពលោក<br>*Church World Service (CWS)*<br>២.អង្គការអភិវឌ្ឍន៍គ្រួសារទន់ខ្សោយ<br>*Weak Family Development Organization (WFD)*<br>៣.អង្គការទ្រទ្រង់ស្ត្រីខ្មែរ<br>*Cambodian Organization for Women Support (COWS)*<br>៤.អង្គការអភិវឌ្ឍន៍ជនក្រីក្រ<br>*Angkar Akphiwat Chon Kreikror (AACK)*<br>៥.អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ<br>*Cambodian League for the Promotion and Defense of Human Rights (LICADHO)*<br>៦.អង្គការអភិវឌ្ឍន៍យុវជនកសិករ<br>*Farmer Youth Development (FYDO)*<br>៧.អង្គការគំរោងការពារក្តីកម្ពុជា<br>*Cambodian Defenders Project (CDP)*<br>៨.អង្គការសង្គ្រោះជនទុរគត និងមនុស្សចាស់<br>*Old ages and Miserable people Help (HOM)*<br>**៩-សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា**<br>*Cambodian Human Rights and Development Association (ADHOC)*<br>**១០-អង្គការអភិវឌ្ឍន៍គ្រួសារ និងយុវជនក្រីក្រ** *(WFYD)* |

| | |
|---|---|
| **ពោធិសាត់** | ១.អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា<br>*Cambodia Family Development Services (CFDS)*<br>២.អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន<br>*Environmental Protection and Development Organization (EPDO)*<br>៣.អង្គការអភិវឌ្ឍន៍ពុទ្ធសាសនា និងទ្រទ្រង់បរិស្ថាន<br>*Buddhism development Association and Supporting Environment (BDASE)* |
| **កំពត** | ១.អង្គការដៃគូអភិវឌ្ឍន៍<br>*(DKA)* |
| **រតនៈគិរី** | ១.គំរោងបណ្តាញការពារទន្លេសេសាន<br>*(Sesan Protection Network)* |
| **បន្ទាយ-មានជ័យ** | ១.អង្គការក្រុមទ្រទ្រង់ភូមិ<br>*Village Support Group (VSG)* |

---

## សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល

**Fisheries Action Coalition Team (FACT)**

អាស័យដ្ឋាន : ផ្ទះលេខ ២៩ ផ្លូវ ៣៣៤ សង្កាត់ បឹងកេងកង ១ ខ័ណ្ឌ ចំការមន ក្រុង ភ្នំពេញ
ទូរស័ព្ទ : (៨៥៥-២៣) ៩៩៤ ០៨៥ ទូរសារ : (៨៥៥-២៣) ៩៩៤ ០៨៥
E-mail : factpp@camnet.com.kh
Website : www.fact.org.kh

## តំលៃទស្សនាវដ្តី

**Subscription Fee**

- ក្នុងស្រុក : ៣៥០០ រៀល ក្នុង ១ច្បាប់
- ក្រៅស្រុក : ៣.០០ ដុល្លាអាមេរិក ក្នុង១ច្បាប់ និងថែម ១ដុល្លាអាមេរិក សំរាប់ថ្លៃផ្ញើរតាមយន្តហោះ
- សំរាប់សហគមន៍នេសាទ និងអង្គការសមាជិកទាំងឡាយរបស់ FACT គឺយើងចែកជូនដោយឥតគិតថ្លៃ



ក្មេងកំពុងយួរសត្វចេញពីព្រៃ

## សេចក្តីជូនដំណឹង

## ទស្សនាវដ្តី សម្លេងប្រជានេសាទ

ជាទស្សនាវដ្ដីអព្យាក្រិត្យផ្សព្វផ្សាយការងារមួយចំនួនដែលពាក់ព័ន្ធនឹងបរិស្ថាន ធនធានធម្មជាតិ ទឹក និង មនុស្ស ។

អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សហគមន៍នេសាទ លោក លោកស្រី អ្នកនាងកញ្ញា និងប្រជានេសាទមានចំណាប់អារម្មណ៍ចង់ចុះផ្សាយអត្ថបទដែលទាក់ទងនឹងវិស័យនេះ ដើម្បីជួយអភិរក្ស អភិវឌ្ឍន៍បរិស្ថាន ធនធានធម្មជាតិ ទឹក និងមនុស្ស សូមមេត្តាផ្ញើរមកកាន់អាស័យដ្ឋានផ្ទះលេខ២៩ ផ្លូវ៣៣៤ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។
☎ ទូរស័ព្ទលេខ : (៨៥៥-២៣) ៩៩៤ ០៨៥ ទូរសារលេខ : (៨៥៥-២៣) ៩៩៤ ០៨៥ ដោយបញ្ជាក់អំពីអត្តសញ្ញាណ អាស័យដ្ឋាន និងលេខទូរស័ព្ទរបស់អ្នកអោយបានច្បាស់លាស់ ។ យើងខ្ញុំសូមធ្វើការជ្រើសរើស និងរក្សាសិទ្ធិផ្ទៀងផ្ទាត់មុននឹងធ្វើការចុះផ្សាយជូន ។

ប្រសិនបើលោក លោកស្រីចង់បានទស្សនាវដ្ដីសម្លេងប្រជានេសាទ សូមមេត្តាធ្វើការទំនាក់ទំនងតាមអាស័យដ្ឋានខាងលើ ។ យើងខ្ញុំរីករាយនឹងទទួលជានិច្ចនូវមតិរិះគន់ក្នុងន័យស្ថាបនា ពីសំណាក់ លោក លោកស្រី ។

**សូមអរគុណ!**